**ក្រសួងអប់រំ យុវជន និងកីឡា**
Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**
National Institute of Education

# និក្ខេបបទ
# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ
# ក្នុងប្រទេសកម្ពុជា
# ករណីសិក្សា៖ ខេត្តបន្ទាយមានជ័យ

The Situation of Teacher Allocation and Utilization at

Secondary Schools in Cambodia

Case Study: Banteay Meanchey Province

**ដោយ**/By
**ឌី សុផល** /DY SOPHALL

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ** (**ជំនាន់ទី៣**)
**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ឆ្នាំសិក្សា ២០១៩ - ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport


វិទ្យាស្ថានជាតិអប់រំ
National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ
# ក្នុងប្រទេសកម្ពុជា
# ករណីសិក្សាៈ ខេត្តបន្ទាយមានជ័យ

## The Situation of Teacher Allocation and Utilization at Secondary Schools in Cambodia

## Case Study: Banteay Meanchey Province


ដោយ/By
**ឌី សុផល** /DY SOPHALL


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ (ជំនាន់ទី៣)

ឯកទេសៈ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា ២០១៩ - ២០២០

សាស្ត្រាចារ្យដឹកនាំៈ បណ្ឌិត នី រដ្ឋា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ:.......✓....... វជអ.**

# លិខិតបញ្ជាក់ និងទទួលស្គាល់

## នាយកវិទ្យាស្ថានជាតិអប់រំ

## សូមបញ្ជាក់ និងទទួលស្គាល់ថា៖

លោក **ឌី សុផល** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែល មានប្រធានបទ **"ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា"** **ករណីសិក្សា ៖ ខេត្តបន្ទាយមានជ័យ** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

# លិខិតបញ្ជាក់

**បណ្ឌិត នី រដ្ឋា** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ឌី សុផល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ជំនាន់ទី៣ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ពិតជា បានសរសេរនិក្ខេបបទស្រាវជ្រាវដែលមានប្រធានបទ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា" ករណីសិក្សាៈ ខេត្តបន្ទាយមានជ័យ** ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**សាស្ត្រាចារ្យណែនាំ**

....................................................

**បណ្ឌិត នី រដ្ឋា**

ប្រធានការិយាល័យសិក្សា

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា៖ "**ស្ថានភាពនៃការប្រើ-ប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា" ករណីសិក្សា៖ ខេត្តបន្ទាយមានជ័យ** ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ជំនាន់ទី៣ ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌ សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយ ត្រូវបានប្រើប្រាស់ក្នុងអត្ថបទសិក្សាស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញថ្ងៃទី ខែ ឆ្នាំ

**ហត្ថលេខា**

**ឌី សុផល**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :៣៣៤.....ខជអ. សក

## លិខិតឧទ្ទេសនាម

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្ដេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្ដមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី ផ្កា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្នី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ រីភា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្នន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន រ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

II. **លេខាធិការ** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ** ហត្ថលេខា

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងជេអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជេអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជេអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឌី សុផល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣នៃវិទ្យាស្ថានជាតិអប់រំ សូមថ្លែងអំណរគុណជាអនេកចំពោះ៖

- លោកឪពុក **ឌី ស៊ុម** និងអ្នកម្ដាយ **ខុង យ៉ែម** ជាអ្នកមានគុណដ៏ថ្លៃថ្លាខ្ពស់បំផុត ដែលបានផ្ដល់កំណើត ចិញ្ចឹមបីបាច់ ផ្ដល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្ដមសិក្សាដោយមិនគិតពីការលំបាក នឿយហត់ ព្រមទាំងតស៊ូគ្រប់បែបយ៉ាងដើម្បីកូនទទួលបានចំណេះដឹង និងមានអនាគតល្អដូចថ្ងៃនេះ។
- លោកស្រី **ឌី សីហៀង** ជាឧត្តមភរិយា និងបុត្រីរបស់ខ្ញុំដែលបានជួយជ្រោមជ្រែងទាំងផ្នែកថវិកា ស្មារតី និងការលើកទឹកចិត្តឱ្យខ្ញុំបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០។
- **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតឱ្យមានថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជាការផ្ដល់ឱកាសឱ្យមន្ត្រីអប់រំបានអភិវឌ្ឍសមត្ថភាពខ្លួនបន្ថែម។
- **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ **លោកគ្រូ អ្នកគ្រូ** ជាសាស្ត្រាចារ្យ បុគ្គលិកនៃវិទ្យាស្ថានជាតិអប់រំដែលបានយកចិត្តទុកដាក់បង្រៀនរហូតដល់ចប់វគ្គប្រកបដោយជោគជ័យ។
- **លោក ឆែម ម៉ូដែល** នាយកវិទ្យាល័យភ្នំធំដែលជាអ្នកផ្ដល់កម្លាំងចិត្ត ជំរុញទឹកចិត្ត ផ្ដល់ការទូន្មានល្អៗដល់ខ្ញុំឱ្យបន្តការសិក្សាវគ្គនាយកនេះរហូតដល់ចប់ និងទទួលបានផ្លែផ្កាល្អ។
- **ឯកឧត្តម លោកគ្រូឧទ្ទេសថ្នាក់ក្រសួង**ទាំងអស់ដែលបានបង្រៀនប្រកបដោយការយកចិត្តទុកដាក់ និងលះបង់កម្លាំងកាយ និងពេលវេលាដ៏មានតម្លៃ មកបណ្ដុះបណ្ដាលវគ្គនេះរហូតដល់ចប់ប្រកបដោយជោគជ័យ។
- សាស្ត្រាចារ្យដឹកនាំ **បណ្ឌិត នី រដ្ឋា** ដែលបានផ្ដល់ការណែនាំ ដំបូន្មានល្អៗ ផ្ដល់ទាំងកម្លាំងចិត្តប្រាជ្ញាស្មារតី ចំណាយពេលវេលាកែសម្រួលជាច្រើនសា បង្ហាញបច្ចេកទេសវិធីសាស្ត្រ និងផ្ដល់ឯកសារពាក់ព័ន្ធផ្សេងៗជាច្រើនរហូតទទួលបានជោគជ័យ។

ជាចុងបញ្ចប់ខ្ញុំបាទសូមគោរពជូនពរ អ្នកមានគុណទាំងពីរ ក្រុមគ្រួសាររបស់ខ្ញុំ លោក លោកស្រី ជាសាស្ត្រាចារ្យ គ្រូឧទ្ទេស លោកគ្រូ អ្នកគ្រូ បុគ្គលិកវិទ្យាស្ថានជាតិអប់រំ និងឯកឧត្តម ទទួលបានសេចក្ដីសុខមានសុខភាពល្អ មានកម្លាំងពលំមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# បញ្ជីតារាង

**ទំព័រ**

តារាងទី 1៖ ការកំណត់ម៉ោងបំពេញកាងាររបស់បុគ្គលិកអប់រំ.....................................................21
តារាងទី 2៖ ម៉ោងប្រចាំសប្តាហ៍សម្រាប់ការបង្រៀនក្នុងថ្នាក់ និងការបំពេញភារកិច្ចរបស់បុគ្គលិកអប់រំ . 22
តារាងទី 3៖ និយាមប្រើបុគ្គលិកបង្រៀន............................................................................ 23
តារាងទី 4៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សាចំណេះទូទៅ................. 23
តារាងទី 5៖ របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី៧ ទី៨ និងទី៩ ................................................. 26
តារាងទី 6៖ កម្មវិធីសិក្សាលម្អិត ផ្នែកមធ្យមសិក្សា................................................................ 27
តារាងទី 7៖ កម្រិតចង្អុលបង្ហាញ ..................................................................................... 37
តារាងទី 8៖ ចំនួនសំណាកដែលត្រូវជ្រើសរើសសាលាក្នុងខេត្តបន្ទាយមានជ័យ .............................. 39
តារាងទី 9៖ ចំនួននាយកសាលាគិតតាមភេទ អាយុ និងរយៈពេលនៃបទពិសោធន៍......................... 44
តារាងទី 10៖ ចំនួនម៉ោងបន្ថែម និងចំនួនវេនបង្រៀន និងរៀន................................................. 45
តារាងទី 11៖ ទីតាំងសាលារៀនរបស់នាយកសាលាដែលបំពេញកម្រងសំណួរ ................................ 45
តារាងទី 12៖ ស្ថិតិសិស្ស ថ្នាក់ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងទូទាំងខេត្ត ............. 46
តារាងទី 13៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកមង្គលបូរី.... 49
តារាងទី 14៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកភ្នំស្រុក ...... 50
តារាងទី 15៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មីនិងតាមជាក់ស្តែងក្នុងស្រុកព្រះនេត្រព្រះ 51
តារាងទី 16៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកអូរជ្រៅ ...... 53
តារាងទី 17៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងក្រុងសិរីសោភ័ណ 54
តារាងទី 18៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកថ្មពួក ........ 55
តារាងទី 19៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកម៉ាឡៃ ....... 56
តារាងទី 20៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកស្វាយចេក . 58
តារាងទី 21៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងក្រុងប៉ោយប៉ែត .. 59
តារាងទី 22៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត........................................................61
តារាងទី 23៖ កម្រិតនៃការអនុវត្តសកម្មភាពលម្អិតលើផ្នែកការប្រើប្រាស់គ្រូបង្រៀន ......................... 62
តារាងទី 24៖ កម្រិតនៃការអនុវត្តសកម្មភាពលើការប្រើប្រាស់គ្រូបង្រៀន......................................... 63
តារាងទី 25៖ ចំនួនគ្រូលើសឬខ្វះតាមមុខវិជ្ជា និងសរុបរួមតាមនិយាមថ្មី....................................... 67

# បញ្ជីក្រាប

ទំព័រ

ក្រាបទី 1៖ ចំនួនគ្រូមានស្រាប់និងតម្រូវការគ្រូតាមនិយាមថ្មីតាមឯកទេសនីមួយៗទូទាំងខេត្ត ...........48

# បញ្ជីអក្សរកាត់

- IIEP — International Institute for Educational Planning
- OECD — the Organization for Economic Co-operation and Development
- SDG — Sustainable Development Goal
- SEAMEO — Southeast Asian Ministers of Education Organization
- SWOT — Strengths Weakness Opportunities Threats
- អយក.សណន — អប់រំ យុវជន និងកីឡា សេចក្តីណែនាំ
- អនក្រ.បក — អនុក្រឹត្យ ប្រកាស
- មស.សណន — មុខងារសាធារណៈ សេចក្តីណែនាំ
- វជអ.ផក — វិទ្យាស្ថានជាតិអប់រំ ផែនការ
- ICT — Information and Communication Technology

# មូលន័យសង្ខេប

ការបែងចែក និងប្រើប្រាស់គ្រូបង្រៀន ដើរតួយ៉ាងសំខាន់ ក្នុងដំណើរបង្រៀននិងរៀន រវាងគ្រូនិងសិស្សដើម្បីសម្រេចបានលទ្ធផលសិក្សាល្អ។ ការសិក្សាស្រាវជ្រាវនេះមានគោលបំណងធំៗចំនួន២ គឺសិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន និងរកឱ្យឃើញពីបញ្ហាប្រឈមនានានៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។

អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រវិភាគបែបបរិមាណវិស័យ និងបែបគុណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ដែលមានសំណួរដើម្បីប្រមូលទិន្នន័យពីគណៈគ្រប់គ្រងនៅតាមវិទ្យាល័យចំនួន ២០ និងអនុវិទ្យាល័យចំនួន៤២ក្នុងចំណោមវិទ្យាល័យចំនួន៣០និងអនុវិទ្យាល័យចំនួន៥៤ក្នុងខេត្តបន្ទាយមានជ័យឆ្នាំសិក្សា២០១៩-២០២០។

អ្នកស្រាវជ្រាវជ្រើសរើសយកសំណាក ចំនួន២០វិទ្យាល័យ និង៤២អនុវិទ្យាល័យក្នុងចំណោមស្រុកក្រុង៩ ដើម្បីប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវទាក់ទងទស្សនៈយល់ឃើញ របស់នាយក/នាយិកាទៅលើការប្រើប្រាស់គ្រូបង្រៀន។ ដោយឡែកអ្នកស្រាវជ្រាវបានប្រមូល ចំនួនសិស្ស ចំនួនថ្នាក់រៀន ចំនួនគ្រូកម្រិតមូលដ្ឋានបានគ្រប់ចំនួនសាលាទាំង៨៤។ បុគ្គលិកសិក្សាជាគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន១៩៤១នាក់ ស្រីចំនួន៨៤០នាក់ ក្នុងនោះមានគ្រូបង្រៀនឈរថ្នាក់ជាក់ស្តែងដែលមិនមែនជាបុគ្គលិកការិយាល័យនៅតាមវិទ្យាល័យចំនួន៣០សាលា និងអនុវិទ្យាល័យ៥៤សាលាមានចំនួន៩៧៦នាក់ ស្រីចំនួន៤២៣នាក់។

ចំពោះការវិភាគទិន្នន័យផងដែរ អ្នកស្រាវជ្រាវបានប្រើប្រាស់ឯកសារយោង៣ជាស្តង់ដារធៀប ដើម្បីឱ្យការវិភាគទៅលើទិន្នន័យតាមនិយាមថ្មីគឺ (១)សេចក្តីណែនាំលេខ២០ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា (២)ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស និង(៣)កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិឆ្នាំ២០១៨។

ស្របពេលជាមួយគ្នា អ្នកស្រាវជ្រាវក៏បានរកឃើញ បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន ដំណោះស្រាយបញ្ហាខាងលើ និងមតិយោបល់បន្ថែមរបស់នាយក/នាយិកាលើការប្រើប្រាស់គ្រូបង្រៀន។

# មាតិកា

**ទំព័រ**

លិខិតបញ្ជាក់ និងទទួលស្គាល់.......................................................i
លិខិតបញ្ជាក់ ....................................................................................... ii
សេចក្តីប្រកាសអះអាងរបស់បេក្ខជន.................................................... iii
លិខិតឧទ្ទេសនាម ................................................................................ iv
សេចក្តីថ្លែងអំណរគុណ......................................................................... vi
បញ្ជីតារាង.........................................................................................vii
បញ្ជីក្រាប .........................................................................................viii
បញ្ជីអក្សរកាត់....................................................................................viii
មូលន័យសង្ខេប.................................................................................... ix
មាតិកា.................................................................................................x
**ជំពូកទី១៖ សេចក្តីផ្តើម** ...................................................................... 1
១.១ សាវតារ ........................................................................................1
១.២ បញ្ហានៃការស្រាវជ្រាវ ......................................................................4
១.៣ គោលបំណងនៃការស្រាវជ្រាវ ............................................................5
១.៤ សំណួរស្រាវជ្រាវ ............................................................................5
១.៥ សារសំខាន់នៃការស្រាវជ្រាវ ..............................................................6
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ...............................................................7
**ជំពូកទី២៖ ការរំលឹកទ្រឹស្តី** ..................................................................8
២.១ និយមន័យ.......................................................................................8
២.២ ការគ្រប់គ្រងបុគ្គលិកអប់រំ ................................................................8

២.៣ ការគ្រប់គ្រងគ្រូបង្រៀន ........................................ 15
២.៣.១ ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ ........................................ 15
២.៣.២ ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា ........................................ 16
២.៣.៣ ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ ........................................ 16
២.៣.៤ ការដោះស្រាយស្ថានភាពលើសឬខ្វះគ្រូបង្រៀន ........................................ 17
២.៣.៥ សាលារៀនលើសគ្រូបង្រៀន ........................................ 18
២.៣.៦ សាលារៀនខ្វះគ្រូបង្រៀន ........................................ 18
២.៤ និយាមប្រើប្រាស់បុគ្គលិកអប់រំតាមនិយាមថ្មី ........................................ 21
២.៤.១ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ និងម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ ........................................ 21
២.៤.២ និយាមប្រើបុគ្គលិកអប់រំតាមគ្រឹះស្ថានសិក្សាសាធារណៈ ........................................ 23
២.៥ មុខវិជ្ជាសិក្សា និងម៉ោងសិក្សានៅមធ្យមសិក្សាមបឋមភូមិ ........................................ 24
២.៦ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា ........................................ 30
២.៦.១ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា ........................................ 30
២.៦.២ ឫសគល់នៃបញ្ហាក្នុងការអប់រំនៅកម្ពុជា ........................................ 32
២.៦.៣ ដំណោះស្រាយបញ្ហាប្រឈមនៃការអប់រំនៅគ្រឹះស្ថានមធ្យមសិក្សា ........................................ 33
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ........................................ 35
៣.១ គម្រោងវិភាគ ........................................ 35
៣.២ ការប្រមូលទិន្នន័យ ........................................ 35
៣.៣ ឧបករណ៍ស្រាវជ្រាវ ........................................ 35
៣.៤ ការជ្រើសរើសភាគសំណាក ........................................ 38
៣.៥ ការវិភាគទិន្នន័យ ........................................ 43
**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ........................................ 44
៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ ........................................ 44
៤.១.១ ពត៌មានទូទៅរបស់អ្នកចូលរួមឆ្លើយ ........................................ 44

៤.១.២ ទីតាំងសាលារៀន........................................................................................................ 45
៤.១.៣ ការកំណត់ពីតម្រូវការគ្រូកម្រិតមូលដ្ឋានទូទាំងខេត្តបន្ទាយមានជ័យ ................................. 46
៤.១.៤ ទស្សនៈរបស់គណៈគ្រប់គ្រងលើកាប្រើប្រាស់គ្រូបង្រៀន .................................................61
៤.១.៥ បញ្ហាប្រឈមនិងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន ................ 64
៤.១.៦ មតិយោបល់បន្ថែមរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន....................................66
**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ**............................................... 69
៥.១ សេចក្តីសន្និដ្ឋាន ............................................................................... 69
៥.២ សំណូមពរ ......................................................................................... 69
ឯកសារយោង ........................................................................................ 72

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ សាវតារ

ការអប់រំ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការចាប់យក វិជ្ជាជីវៈប្រចាំជីវិត និងបង្កើនសមត្ថភាព ដើម្បីប្រកបការងារ ក៏ដូចជាបន្តការសិក្សារៀនសូត្រទៅថ្នាក់លើទៀត។ ការពង្រឹងមូលដ្ឋានគ្រឹះនៃការអប់រំ និងការបង្កើតលក្ខខណ្ឌអំណោយផលដល់យុវជន យុវនារីក្នុងការចូលរួមអភិវឌ្ឍសង្គមសេដ្ឋកិច្ចផ្អែកលើចំណេះដឹង គឺជាគោលដៅរបស់ប្រទេសនីមួយៗនៅក្នុងសកលលោកយើងនេះ។ ប្រទេសជាតិមួយអាចរីកចម្រើនទៅបាន អាស្រ័យទៅលើសម្បទាពេញលេញនៃធនធានមនុស្សរបស់ប្រទេសនោះ ពោលគឺមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាល្អ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥)។ ក្នុងន័យនេះគ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ព្រោះពួកគេជាអ្នកផលិតធនធានមនុស្សសម្រាប់ឱ្យទៅបម្រើការងារនៅគ្រប់វិស័យក្នុងសង្គម ហើយក៏ជាវិស្វករនៃព្រលឹង ដែលរដ្ឋបានផ្តល់ទំនុកចិត្តឱ្យបង្រៀននិងអប់រំយុវជន យុវនារី ដែលជាសសរទ្រូងដ៏មានតម្លៃមិនអាចកាត់ថ្លៃបានចំពោះគ្រួសារ និងសង្គមជាតិទាំងមូល។ អនាគតប្រទេសជាតិអាស្រ័យទាំងស្រុងទៅលើគ្រូបង្រៀន។ ប្រទេសជាតិទទួលបានការរីកចម្រើនឬមានភាពទន់ខ្សោយ អាស្រ័យទៅលើគុណភាពនៃការអប់រំ ជាពិសេសអាស្រ័យទៅលើធនធានមនុស្សដែលគ្រូបង្រៀនគ្រប់កម្រិត និងគ្រប់វិស័យផលិតបាន។ វិស្វករសំណង់ម្នាក់បំពេញភារកិច្ចរបស់ខ្លួនមិនបានល្អធ្វើការខ្ជីខ្ជា ការខូចខាតមានតែសម្ភារប៉ុណ្ណោះ ឬបើធ្ងន់ធ្ងរជាងនេះទៅទៀតវិនាសតែគ្រួសារមួយប៉ុណ្ណោះ។ ផ្ទុយទៅវិញគ្រូបង្រៀនម្នាក់ ដែលខ្វះចំណេះដឹង ខ្វះសីលធម៌ ហើយបំពេញភារកិច្ចរបស់ខ្លួនមិនបាន ផ្តល់ការអប់រំគ្មានគុណភាព ឬផលិតធនធានមនុស្សមិនទទួលបានសម្បទាពេញលេញ អ្នកដែលត្រូវទទួលផលវិបាកអាក្រក់ គឺមនុស្សជាតិទាំងមូល ពិសេសគឺយុវជន យុវនារីដែលជាសសរទ្រូងរបស់ប្រទេសជាតិហើយប្រទេសជាតិទាំងមូល នឹងត្រូវទទួលផលវិបាកអាក្រក់ជាក់ជាមិនខាន (រាជរដ្ឋាភិបាល ២០១៨)។

សម្រាប់បរិបទកម្ពុជា ដើម្បីធានាឱ្យបានថា កម្ពុជាប្រាកដជាអាចទទួលបានជោគជ័យ ជាមួយនឹងការប្រណាំងប្រជែងយ៉ាងមុតមាំក្នុងសេដ្ឋកិច្ចសកល ភាវូបនីយកម្ម ការពង្រឹងគុណភាពនិងភាពឆ្លើយតប

នៃវិស័យអប់រំ គឺជាលក្ខខណ្ឌមួយមិនអាចខ្វះបាននាពេលបច្ចុប្បន្ន។ សម្រេចបាននូវទិសដៅនេះគ្រូបង្រៀន ជាតួអង្គដ៏សំខាន់ ព្រោះវិជ្ជាជីវៈនេះ ជាអ្នកបើកច្រក សម្រាប់បង្ហាត់បង្រៀនវិជ្ជាជីវៈផ្សេងៗទៀត។ ប្រសិនបើគ្មានគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀននោះទេ កម្ពុជាមិនអាចសម្រេចបានគោលដៅ ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាពខ្ពស់ដល់សិស្ស និងនិស្សិតបានឡើយ។ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងមានទេពកោសល្យ ក្នុងការបង្ហាត់បង្រៀន គឺជាកត្តាដ៏សំខាន់បំផុតក្នុងការធ្វើឱ្យសម្រេចបាន នូវគោលនយោបាយអប់រំ របស់កម្ពុជាដែលរួមមានៈ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ក៏ដូចជាធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ជាដើម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។ ពិសេសជាងនេះទៅទៀត បើគ្មានគ្រូបង្រៀននោះទេ ក៏គ្មានការអប់រំពេញមួយជីវិត ហើយក៏គ្មានសង្គមពុទ្ធិ និងវិបុលភាពនោះដែរ។ ដើម្បីទៅដល់គោលដៅនេះទាមទារឱ្យការបែងចែកនិងគ្រប់គ្រងគ្រូបង្រៀនមានប្រសិទ្ធភាព ព្រោះវាជាកូនសោគន្លឹះដើម្បីសម្រេចបាននូវគោលដៅខាងលើ។ បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ជាច្រើន ដើម្បីធានានូវការពង្រឹងគុណភាពអប់រំឱ្យសមស្របទៅនឹង និន្នាការអប់រំក្នុងតំបន់ និងពិភពលោកនាសតវត្សន៍ទី២១។ ឯកសារគតិយុត្តជាច្រើន ពិសេសគោលនយោបាយគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងគន្លងអាជីពគ្រូបង្រៀន ត្រូវបានបង្កើតឡើងក្នុងន័យជួយសម្រួលដល់ការជ្រើសរើសការបណ្តុះបណ្តាល ការបែងចែក និងការគ្រប់គ្រងគ្រូបង្រៀនឱ្យមានលក្ខណៈល្អប្រសើរ ព្រោះប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀន ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការជ្រើសរើស ការបណ្តុះបណ្តាល ការលើកទឹកចិត្ត ការពង្រាយ ការរក្សា ការផ្ទេរ ឬការផ្លាស់ប្តូរជាដើម។ ក្នុងន័យនេះ តម្រូវការនៃការប្រើប្រាស់គ្រូបង្រៀន ឱ្យមានប្រសិទ្ធភាព មានសារៈសំខាន់ណាស់ដល់គុណភាពអប់រំ ហើយពាក់ព័ន្ធទៅ នឹងកត្តាជាច្រើនដូចជា៖ ការបង្កើនជាតុចូលនិងការបន្ថយនិយាមសិស្ស-ថ្នាក់ ឬសិស្ស-គ្រូជាដើម។ យោងតាមរបាយការណ៍OECD (2005) បានបង្ហាញឱ្យឃើញថាគ្រូបង្រៀនគឺជាកម្លាំងពលកម្មដ៏ធំមួយ ធៀបទៅនឹងវិស័យផ្សេងៗទៀត ហើយការចំណាយចរន្តភាគច្រើនក្នុងវិស័យនេះ គឺប្រាក់ខែរបស់បុគ្គលិកអប់រំ។ តាមរបាយការណ៍ដដែលក៏បានបង្ហាញផងដែរថា ដើម្បីបង្កើនចំណាប់អារម្មណ៍លើអាជីពគ្រូបង្រៀន ឱ្យមានការប្រកួតប្រជែង ក្នុងទីផ្សារការងារលើវិស័យនេះ គឺត្រូវផ្តល់ឋានៈដល់គ្រូបង្រៀន ឬសង្គមត្រូវឱ្យ

តម្លៃខ្ពស់ទៅដល់ គ្រូបង្រៀន។ ការពង្រីកធនធានលើផ្នែកផ្គត់ផ្គង់ពីប្រភពផ្សេងៗ ក៏ដូចជាការជ្រើសរើសមនុស្សមានសមត្ថភាពឱ្យចូលធ្វើ គ្រូបង្រៀន អាចធ្វើទៅបានតាមរយៈការបង្កើនប្រាក់លើកទឹកចិត្ត និងប្រាក់គាំទ្រ ជាពិសេសដល់អ្នកដែលស្ម័គ្រចិត្តទៅបង្រៀននៅតំបន់ដាច់ស្រយាល និងជួបការលំបាក ព្រោះថាគ្រូបង្រៀនគឺជាមូលដ្ឋានគ្រឹះនៅក្នុងដំណើរការបង្ហាត់បង្រៀន ហើយគុណភាពនៃការបង្រៀន គឺជាកត្តាដែលកំណត់ឱ្យគុណភាពនៃការអប់រំដោយសារគ្រូបង្រៀនគឺជាកត្តាចម្បងដែលជះឥទ្ធិពល ទៅដល់គុណភាពនៃការអប់រំ។ គ្រូបង្រៀន គឺជាបេះដូងក្នុងដំណើរការរៀនសូត្រ ហើយក៏មានឥទ្ធិពលទៅលើគុណភាព និងលទ្ធផលសិក្សារបស់សិស្សផងដែរ។ ការគ្រប់គ្រងគ្រូមានប្រសិទ្ធភាពមានសារៈសំខាន់ ក្នុងការសម្រេចបានជោគជ័យនៅក្នុងប្រព័ន្ធគ្រប់គ្រងអប់រំ។ ប្រសិទ្ធភាពនៃការចំណាយក៏រិតតែសំខាន់ ព្រោះបើផ្អែកតាមរបាយការណ៍របស់ បណ្តាប្រទេសជាច្រើន តួលេខចំណាយជាក់ស្តែង ទៅលើប្រាក់បៀវត្សរបស់គ្រូបង្រៀនស្រូបអស់ពីរភាគបី (២/៣) នៃការចំណាយសរុបលើវិស័យនេះ (IIEP 2015)។ ដើម្បីឱ្យដំណើរការនៃការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀន នៅកម្រិតអនុវិទ្យាល័យមានប្រសិទ្ធភាពខ្ពស់ មន្ត្រីគ្រប់គ្រងអប់រំ ជាពិសេសនាយកសាលា និងផ្នែកបុគ្គលិក ត្រូវរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម។ ការធ្វើហេតុវិនិច្ឆ័យពីតម្រូវការគ្រូ ការកំណត់ចំនួនកូតាការប្រើប្រាស់ និងសុក្រឹតភាពនៃការបែងចែកគ្រូបង្រៀនដែលជាសូចនាករគន្លឹះ ក្នុងការចង្អុលបង្ហាញពីកម្រិតនៃការប្រើប្រាស់ធនធាន និងការខាតបង់កម្លាំងពលកម្ម ក៏ជាកត្តាចាំបាច់បំផុតផងដែរ។

ការរៀបចំផែនការរយៈពេលមធ្យម វែង និងការរៀបចំផែនការតាមបែបបរិមាណ អាចប៉ះពាល់ដល់តម្រូវការលើកម្មវិធីគោលនយោបាយអប់រំ និងការអប់រំ សម្រាប់ការអភិវឌ្ឍប្រកប ដោយចីរភាព។ ការព្យាករណ៍តម្រូវការគ្រូតាមវិធីធ្វើចំណោល ក៏ជាគន្លឹះ និងដំណោះស្រាយសមហេតុផលមួយ ក្នុងការដឹងពីតម្រូវការគ្រូរយៈពេលវែង។ ក្រមសីលធម៌ក្នុងការអនុវត្តការងារ សមត្ថភាពមន្ត្រីគ្រប់គ្រងពុំបានទទួលការបណ្តុះបណ្តាលស្តីពីជំនាញគ្រប់គ្រងធនធានមនុស្ស បញ្ហាអវត្តមានគ្រូកង្វះធនធាន តួនាទី និងការទទួលខុសត្រូវត្រួតគ្នា ទំនាក់ទំនងមិនច្បាស់លាស់លើការវាយតម្លៃ និងការសម្រេចចិត្តមិនដូចគ្នានាំឱ្យការគ្រប់គ្រងគ្រូបង្រៀនមិនទាន់មានប្រសិទ្ធភាព។ ចំណែកឯគ្រូបង្រៀនជ្រើសយកតែប៉ុស្តិ៍នៅទីក្រុងឬទីប្រជុំជន ការផ្លាស់ប្តូរតាមសហព័ទ្ធ ជាពិសេស នៅពេលដែលលក្ខខណ្ឌរស់នៅរបស់គ្រូបង្រៀន និងការ

លើកទឹកចិត្តគ្រូបង្រៀន នៅមានកម្រិតដោយប្រាក់ខែនៅទាប ហើយគ្រូស្រីជាទូទៅមិនជ្រើសរើសយកប៉ុស្ដិ៍នៅជនបទ ក៏ជាបញ្ហាប្រឈមផងដែរ។

## ១.២ បញ្ហានៃការស្រាវជ្រាវ

គ្រូបង្រៀនគឺជាបេះដូងនៃដំណើរការសិក្សា។ ពួកគេជះឥទ្ធិពលយ៉ាងខ្លាំងទាំងគុណភាពនៃ ការអប់រំដែលកុមារទទួលបាន នៅសាលារៀនហើយនៅទីបំផុតលទ្ធផល នៃការសិក្សារបស់ពួកគេ។ ការគ្រប់គ្រងគ្រូប្រកបដោយប្រសិទ្ធភាព មានសារៈសំខាន់ណាស់ សម្រាប់ភាពជោគជ័យ នៃប្រព័ន្ធអប់រំណាមួយ។ ការគ្រប់គ្រងគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពគឺ សំខាន់ជាងនេះទៅទៀតដោយសារគ្រូមានចំណែកសំខាន់សម្រាប់មន្ត្រីរាជការ។ ទោះយ៉ាងណាក៏ដោយរដ្ឋាភិបាលបានប្រឈមមុខនឹងបញ្ហាប្រឈមកាន់តែខ្លាំងឡើងនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះខណៈពេលគ្រប់គ្រងបុគ្គលិកបង្រៀនរបស់ពួកគេ។ ដើម្បីពង្រីកលទ្ធភាពទទួលបានការអប់រំយ៉ាងឆាប់រហ័ស ប្រទេសនានាបានដាក់ប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ខ្លួនឱ្យស្ថិតក្នុងស្ថានភាពតានតឹង។ ក្រសួងនានាត្រូវឆ្លើយតបទៅនឹងតំរូវតម្រូវការរបស់គ្រូដែលកំពុងកើនឡើងស្របពេលជាមួយគ្នានេះដែរព្យាយាមធានាបាននូវគុណភាពដូចគ្នា។ បន្ថែមលើបញ្ហាប្រឈមទាក់ទងនឹងការផ្គត់ផ្គង់និងការបណ្តុះបណ្តាលគ្រូនានាប្រទេសនានាត្រូវដោះស្រាយបញ្ហាទាក់ទង នឹងការបែងចែកនិងការប្រើប្រាស់គ្រូដោយសមធម៌នៅទូទាំងតំបន់ផ្សេងៗគ្នា។ អវត្តមានរបស់គ្រូការយកចិត្តទុកដាក់ខ្ពស់និងការលើកទឹកចិត្តទាបគឺ ជាបញ្ហាមួយដែលអ្នករៀបចំផែនការអប់រំ ត្រូវបានលាតត្រដាងតាមរបៀបមួយឬផ្សេងទៀតនៅក្នុងស្ទើរតែគ្រប់ប្រទេសទាំងអស់នៅជុំវិញពិភពលោក។

ចាប់តាំងពីឆ្នាំ២០១៤មករាជរដ្ឋាភិបាលក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងធ្វើកំណែទម្រង់វិស័យអប់រំកម្ពុជា ស្របពេលដែលមហាជនបានងាកមកចាប់អារម្មណ៍ទៅលើគុណតម្លៃរបស់បុគ្គលិកសិក្សា ឬអាជីពជាគ្រូបង្រៀនគ្រប់កម្រិតសិក្សាទូទាំងប្រទេស។ ជាលទ្ធផលធ្វើឱ្យការសិក្សាអប់រំមានលក្ខណៈល្អប្រសើរបន្តិចម្តងៗ។ ទន្ទឹមពេលជាមួយគ្នានេះ ក្រសួងអប់រំយុវជន និងកីឡាបានបង្កើតកម្មវិធីវិក្រឹតការជាបន្តបន្ទាប់ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំ នៅតាមបណ្ដាអនុវិទ្យាល័យនានាក្នុងទូទាំងប្រទេស។ ប៉ុន្តែបើទោះបីជាមាន ការធ្វើវិក្រឹតការ យ៉ាងដូច្នេះក្តី ក៏សមត្ថភាពអ្នកគ្រប់គ្រងទាំងនោះនៅមានកម្រិត និងពុំទាន់ឆ្លើយតបទៅ នឹងការកែទម្រង់របស់ក្រសួងនៅឡើយ ជាហេតុបណ្តាល

ឱ្យ ស្ថានភាពនៃការប្រើប្រាស់ និងបែងចែកគ្រូបង្រៀនអាចជួបប្រទះនូវ បញ្ហាប្រឈមហើយក៏ជាកត្តាមួយដែលធ្វើឱ្យគុណភាពនៃការអប់រំធ្លាក់ចុះខ្លះផងដែរ។ រហូតមកដល់ពេលនេះ នៅមិនទាន់មានការសិក្សាណាមួយបានបង្ហាញពីស្ថាន ភាពនៃការប្រើប្រាស់គ្រូនៅអនុវិទ្យាល័យនៅឡើយ។ វិធីគណនាតម្រូវការគ្រូនៅអនុវិទ្យាល័យ មិនទាន់ឯកភាពគ្នាឬមិនទាន់មាន រូបមន្តច្បាស់លាស់នៅឡើយ។ ម្យ៉ាងវិញទៀត ការស្នើសុំ និងការផ្តល់គ្រូបង្រៀនមិនទាន់ស្របតាមតម្រូវការ ជាហេតុនាំទៅដល់ការខ្វះគ្រូ ឬលើសគ្រូតាមមុខវិជ្ជាឯកទេស។ មុខវិជ្ជាខ្វះ នៅតែខ្វះ ហើយមុខវិជ្ជាលើស នៅតែបន្តលើសដដែល។ កង្វះខាតប្រព័ន្ធព័ត៌មានវិទ្យា ផែនទីសាលារៀន អត្រាវិចរិល អត្រាគ្រូវិលចូលក្នុងប្រព័ន្ធវិញអត្រាគ្រូបង្រៀនចូលនិវត្តន៍ អត្រាកំណើនសិស្សក្នុងតំបន់និងបទបញ្ញត្តិមិនសមស្របធ្វើឱ្យមានបញ្ហាលើស ឬខ្វះគ្រូបង្រៀនទៅតាមតំបន់។ ដូច្នេះការសិក្សាស្រាវជ្រាវនេះ ផ្តោតជាសំខាន់ទៅលើ ការបែងចែក និងការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនានា ក្នុងប្រទេសកម្ពុជា។ ដើម្បីរួមចំណែកក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ ទើបអ្នកសិក្សាស្រាវជ្រាវលើកយកប្រធានបទស្រាវជ្រាវមួយនេះ ៉ស្ថានភាពការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ៉។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

អ្នកស្រាវជ្រាវមានគោលបំណងធំៗចំនួន២ ចំពោះការសិក្សាស្រាវជ្រាវនេះ៖

(១) សិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។

(២) រកឱ្យឃើញពីបញ្ហាប្រឈមនានា នៃការប្រើប្រាស់គ្រូបង្រៀន នៅតាមអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងស្រាវជ្រាវទាំងនេះ អ្នកស្រាវជ្រាវបង្កើតសំណួរស្រាវជ្រាវចំនួន២ដែរ៖

(១) តើស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យមានលក្ខណៈដូចម្តេច?

(២) តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ?

## ១.៥ សារសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ នឹងផ្តល់ព័ត៌មានស្តីពីការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ) រួមទាំង បញ្ហាប្រឈមនានា និងដំណោះស្រាយ ទៅលើការប្រើប្រាស់គ្រូបង្រៀន នៅតាមវិទ្យាល័យ និងអនុ-វិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ។ ការសិក្សាស្រាវជ្រាវនេះមានសារៈប្រយោជន៍ដូចជា៖(១)ជាទិន្នន័យផ្ទាល់ជាក់ស្តែងស្តីពីការប្រើប្រាស់គ្រូបង្រៀនមកម្រិតមូលដ្ឋាននៅវិទ្យាល័យនិងអនុវិទ្យាល័យនានាក្នុងខេត្តបន្ទាយមានជ័យ (២)ជាលទ្ធផលនៃនិក្ខេបបទបញ្ចប់វគ្គសិក្សាបានជោគជ័យ (៣) ជាការរួមចំណែកមួយជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ជាយោបល់ដល់អ្នកធ្វើគោលនយោបាយអប់រំ ក្នុងការកាត់បន្ថយនូវបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀនទាំងនោះ (៤)ជាចំណេះដឹងថ្មីសម្រាប់វិស័យអប់រំពាក់ព័ន្ធនឹងការបង្កើន និងពង្រឹងគុណវុឌ្ឍគ្រូបង្រៀនកម្រិតមូលដ្ឋាន និង (៥) ជាជំនួយដល់ការស្រាវជ្រាវបន្តលើប្រធានបទដែលលក្ខណៈប្រហាក់ប្រហែលគ្នានៅថ្ងៃខាងមុខ។

## ១.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែទៅលើការប្រើប្រាស់គ្រូមធ្យមសិក្សាបឋមភូមិក្នុងខេត្តបន្ទាយមានជ័យ ប៉ុណ្ណោះ សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ មិនផ្តោតទៅលើអ្វីក្រៅពីនេះឡើយ។ ការស្រាវជ្រាវត្រូវធ្វើឡើងនៅក្នុងខេត្តនេះ ព្រោះជាតំបន់ដែលអ្នកស្រាវជ្រាវកំពុងបម្រើការងារក្នុងវិស័យអប់រំនេះ ហើយមានភាពងាយស្រួលច្រើន ក្នុងការប្រមូលយកព័ត៌មានផ្សេងៗផ្នែកអប់រំ ជាពិសេសការចុះទៅប្រមូលព័ត៌មាននៅតាមវិទ្យាល័យដែលមានអនុវិទ្យាល័យ និងអនុវិទ្យាល័យក្នុងខេត្ត។

### សំណាកសាកល និងសំណាកស្រាវជ្រាវ

ទូទាំងខេត្តបន្ទាយមានជ័យមាន មានក្នុងស្រុកចំនួន៧ និងក្រុង២ មានបុគ្គលិកសិក្សាជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន១៩៤១នាក់ ស្រីចំនួន៨៤០នាក់ ក្នុងនោះមានគ្រូបង្រៀនឈរថ្នាក់ជាក់ស្តែងដែលមិនមែនជាបុគ្គលិកការិយាល័យនៅតាមវិទ្យាល័យចំនួន៣០សាលា និងអនុវិទ្យាល័យ៥៤សាលាមានចំនួន៩៧៦នាក់ ស្រីចំនួន៤២៣នាក់។ ដោយសារសាលាមានចំនួនសរុប៨៤ ដូច្នេះអ្នកស្រាវជ្រាវ ត្រូវជ្រើសរើសសំណាក ដូចតទៅ៖ នាយក/នាយិកាចំនួន ៦២នាក់ តែប៉ុណ្ណោះ ដើម្បីបំពេញកម្រងសំណួរ និងធ្វើសម្ភាសន៍។

ការជ្រើសរើសសំណាក់នេះគឺយោងតាមរូបមន្ត Yamane (Glenn D. Israel, 1992) ដែល nគឺជាសំណាកដែលមានភាពជឿជាក់ Nគឺជាចំនួនសំណាកទាំងអស់ និង eគឺជាកម្រិតមិនច្បាស់លាស់ ។

ដោយ N=84 និង យក e=0.06=6% នោះយើងបាន n= 64 = 94%។ ដូច្នេះហើយអ្នកស្រាវជ្រាវបានជ្រើសរើសសំណាក់តែ៦២សាលា ដែលតិចជាងសំណាក់តាមដែលមានភាពជឿជាក់តែ២សាលា។

រូបមន្តYamane

$$\boldsymbol{n = \frac{N}{1 + N * (e)^2}}$$

$$\mathrm{n} = \frac{84}{1+(84\ x\ 0.06^2)} \approx 64$$

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទស្រាវជ្រាវជ្រាវនេះ ចែកចេញជា៥ជំពូក។ ជំពូកទី១ បង្ហាញពីសាវតារ បញ្ហានៃការស្រាវជ្រាវ គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់ ទំហំ និងកម្រិតនៃការស្រាវជ្រាវ ដែលនៅក្នុងនោះមានទាំងខ្លឹមសារ អថេរ សំណាកសាកល សំណាកស្រាវជ្រាវ។ ជំពូកទី២ បង្ហាញពីនិយមន័យនៃស្ថានភាពការប្រើប្រាស់ព្រមទាំងនិយមន័យពាក់ព័ន្ធនឹងជាតុសំខាន់ទាំងនេះដោយផ្អែកលើទ្រឹស្តីផ្សេងៗ ឯកសារ និងសេចក្តីណែនាំរបស់ក្រសួងអប់រំ ។ លើសពីនេះជំពូកទី២នេះលើកឡើងពីការស្រាវជ្រាវកន្លងមកពាក់ព័ន្ធទៅនឹង ការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅអនុវិទ្យាល័យ ព្រមទាំងខ្លឹមសារសង្ខេបស្តីពីការរំលឹកទ្រឹស្តី និងគំនិតវិភាគលើក្របខ័ណ្ឌស្រាវជ្រាវ។ ជំពូកទី៣បង្ហាញពីការរៀបចំស្រាវជ្រាវ សំណាកសាកល និងសំណាកស្រាវជ្រាវ ឧបករណ៍ស្រាវជ្រាវ (កម្រងសំណួរនិងសម្ភាសន៍)ប្រសិទ្ធភាពនៃឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យនិងការ វិភាគទិន្នន័យ។ ជំពូកទី៤ បង្ហាញពីលទ្ធផលនៃការស្រាវជ្រាវ ដូចជាទិន្នន័យរួមស្តីពីសំណាកនាយក/នាយិកាតារាងទិន្នន័យបែបបរិមាណនិងគុណវិស័យដែលឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរ នៅក្នុងជំពូកទី១និងធ្វើប្រៀបធៀបលទ្ធផលដែលបានរកឃើញជាមួយសម្មតិកម្ម និងធ្វើការពិភាក្សាលើ សំណួរស្រាវជ្រាវទាំងពីរ។ ជំពូកទី៥ចុងក្រោយ បង្ហាញពីការសន្និដ្ឋាន សំណូមពរដល់ ក្រសួងអប់រំ មន្ទីរអប់រំខេត្ត គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងអ្នកស្រាវជ្រាវបន្តក្រោយៗទៀត។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

## ២.១ និយមន័យ

ដើម្បីយល់ច្បាស់ឱ្យបានស៊ីជម្រៅ ទៅលើការបកស្រាយប្រធានបទស្រាវជ្រាវ ជាដំបូងត្រូវយល់ពីអត្ថន័យនៃពាក្រគន្លឹះមួយចំនួនដូចខាងក្រោម៖

**ស្ថានភាព** ("*ស្ថាន*" មានន័យថា ទីកន្លែង ផ្សំជាមួយពាក្រ "*ភាព*"មានន័យថា សភាព លក្ខណៈដំណើរទំនង)មានន័យជារួមថា*សភាពលក្ខណៈនៃទីតាំងជាក់លាក់ណាមួយ*។ នេះបើយោងទៅតាម វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួនណាត ឆ្នាំ២០១៩។ តាមរយៈវចនានុក្រម Oxford Advanced Learner's Dictionary ឆ្នាំ២០០៧ បានផ្តល់អត្ថន័យនៃពាក្យ **ស្ថានភាព** ថាគឺជា *កាលៈទេសៈ និងរឿងរាវដែលបានកើតមាន ក្នុងពេលវេលា និងទីកន្លែងជាក់លាក់ណាមួយ។*

**គ្រូ** នាមសព្ទ (បា. គរុ; សំ. គុរុ = គរ > គ្រ, + ុ > ូ = គ្រូ) អ្នកដែលមានចិត្តធ្ងន់; អ្នកដែលគួរគេគោរពគឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗដល់សិស្ស (ជួន ណាត ១៩៦៧)។

**គ្រូបង្រៀន**សំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ (រាជរដ្ឋាភិបាល ២០១៨)។

**ប្រើប្រាស់** គឺជាប្រើ និងផ្តល់នូវអ្វីមួយដើម្បីសម្រេចគោលបំណងដែលបានគ្រោងទុក (Longman Dictionary 2010)។

**ការប្រើប្រាស់** សំដៅលើនិយាមប្រើប្រាស់បុគ្គលិកអប់រំដើម្បីធ្វើឱ្យប្រសើរឡើងលើការគ្រប់គ្រងនិងការបែងចែកភារកិច្ច ជូនបុគ្គលិកអប់រំដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋបាល និងតាមគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាពស្របទៅនឹងបរិបទនៃក្រសួងអប់រំបច្ចុប្បន្ន (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

## ២.២ ការគ្រប់គ្រងបុគ្គលិកអប់រំ

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់ និងសកលលោក ដែលមានមហិច្ឆតានិងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើ

គ្រប់ប្រភេ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមាន ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ ខាងមុខ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។

វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្នតាម រយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។

ក្នុងន័យនេះ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាពគុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។

សាលារៀន គឺជាកោសិកាស្នូលនៃប្រព័ន្ធអប់រំ។ សាលារៀនល្អ គឺសាលាដែលគណៈគ្រប់គ្រង និងគ្រូគោរពបានយ៉ាងពេញលេញនូវតម្លៃជាមូលដ្ឋាន មានបេសកកម្មច្បាស់លាស់ កំណត់នូវលទ្ធផលខ្ពស់ដែលគ្រូ និងសិស្សត្រូវសម្រេចឱ្យបាន និងត្រូវមាននាយកដែលមានសមត្ថភាពក្នុងការដឹកនាំអនុវត្តនូវទស្សនវិស័យនេះ។ លទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤ គឺៈ (១) នាយកល្អ (២)គ្រូល្អ (៣)សិស្សល្អ (៤)មាតាបិតា និង (៥) សហគមន៍ល្អ (ហាង់ជួន ណារ៉ុន ២០២០)។

ចង់បានសេចក្តីស្រឡាញ់ពីគ្រូ តើនាយកបានលះបង់ក្តីស្រឡាញ់ឱ្យគ្រូដែរឬទេ?

ដើម្បីឱ្យដំណើរការនៃវិធានការគ្រប់គ្រងលើការប្រើប្រាស់ ដឹកនាំបុគ្គលិកសិក្សាក្នុងវិទ្យាល័យមួយ ទទួលបានលទ្ធផលជាផ្លែផ្កា ពោរពេញដោយទំនុកចិត្ត នាយកសាលាត្រូវមាន ជំនាញ និង សមត្ថភាពសំខាន់ៗ ដូចខាងក្រោម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)៖

## ១ កម្រិតវប្បធម៌ និងបទពិសោធការងារ

- បរិញ្ញាបត្រជាន់ខ្ពស់ទាបបំផុត
- វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលា
- មានចំណេះដឹងទូលំទូលាយ(ចំណេះដឹងទូទៅ និងចិត្ត គរុកោសល្យ)
- ចំណេះដឹងផ្នែក ICT
- ចំណេះដឹងភាសាបរទេស
- បទពិសោធបំពេញការងារច្រើនយ៉ាងតិច៥ឆ្នាំ (SEAMEO 2011) ។

## ២ ស្គាល់ខ្លួនឯង  សមត្ថភាព និងគុណសម្បត្តិ

- **ការស្គាល់ និងគោរពខ្លួនឯង**

- អ្វីៗ ទាំងអស់ចាប់ផ្តើមពីយើងម្នាក់ៗ
- មុនពេលគិតថានឹងជួយគេយើងត្រូវតែគិតពីខ្លួនឯងជាមុនសិន (នេះគឺគ្រាន់តែចង់បញ្ជាក់ឱ្យបានច្បាស់ថាតើយើងខ្លួនឯងហ្នឹងមានសុវត្ថិភាព និងមានកម្លាំងគ្រប់គ្រាន់ហើយឬនៅ)
- ត្រូវធ្វើការវិភាគជាប្រចាំពី (១) ចំណុចខ្លាំង (២) ចំណុចខ្សោយ (៣) ឱកាស និង (៤)ឧបសគ្គ ឬបញ្ហាប្រឈម (SWOT) ដែលខ្លួនឯងមាន និងកំពុងជួបប្រទះ
- ការទទួលស្គាល់ ការគោរព គឺជាវិធីមួយដែលធ្វើឲ្យជីវិតរស់នៅរបស់មនុស្សម្នាក់ៗពេញទៅដោយអត្ថន័យ
- ត្រូវមានទស្សនៈវិស័យ ឬគោលដៅច្បាស់លាស់
- មានជីវិតរស់នៅប្រកបដោយគោលដៅ មានការរៀបចំផែនការ មានចក្ខុវិស័យ មិនចុះញ៉មនឹងបរាជ័យ និងមានក្តីសង្ឃឹមជានិច្ចថាការស្រមើស្រមៃនោះនឹងក្លាយជាការពិតនៅថ្ងៃណាមួយជាក់មិនខាន

- ការមានទស្សនៈវិស័យ នាំមកនូវជោគជ័យពិតប្រាកដក្នុងជីវិត និងក៏ជាជោគជ័យដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ព្រោះវាចាប់ផ្ដើមមកពីសុបិន និងការខំធ្វើឲ្យក្លាយជាការពិតបាន ដោយខ្លួនគេផ្ទាល់ ដែលមិនមែនជាជោគជ័យបានមកពីភាពចៃដន្យ នោះឡើយ
- មនុស្សដែលមានទស្សនវិស័យ មិនធ្វើអ្វីដើម្បីតែថ្ងៃនេះនោះទេ តែនឹងធ្វើដើម្បីថ្ងៃស្អែក និងថ្ងៃខាងមុខទៀតផងដែរ
- វាពិតជារឿងសំខាន់ខ្លាំងណាស់ ដែលបុគ្គលម្នាក់ៗ មានទស្សនវិស័យក្នុងជីវិត ព្រោះនោះជាកម្លាំងដ៏សំខាន់ដែលផ្ដល់ឱ្យខ្លួនឯង គ្រួសារ អង្គភាពសង្គម ឬប្រទេសជាតិ ឱ្យសម្រេចបានជោគជ័យ និងការអភិវឌ្ឍ (នូវ រីា ២០១៩)។

- **មានក្រមសីលធម៌វិជ្ជាជីវៈ**

- មនសិការវិជ្ជាជីវៈជាគ្រូបង្រៀន
- ពង្រឹងសាមគ្គីភាពផ្ទៃក្នុង
- គោរពវិន័យការងារ
- ភក្ដីភាពចំពោះអង្គភាព
- ក្លាហាន
- មិនអត្មានិយម
- មានឆន្ទៈ
- អត់ធ្មត់ គ្មានហិង្សា
- ឧស្សាហ៍ព្យាយាម
- ស្មោះត្រង់
- មានការលះបង់។

- **ភាពជាអ្នកដឹកនាំ**

– មេគុណៈ បំពេញគ្រប់កិច្ចការមុននិងច្រើនជាងអ្នកក្រោមបង្គាប់(មុនគេ)អ្វីៗទាំងអស់ចាប់ផ្ដើមពីយើងម្នាក់ៗមុន

– មេគិត ៖ កិច្ចការត្រូវគិតមុននិងចូលរួមជាមួយបុគ្គលិកដោយសមធម៌ (មិត្តគេ)

– មេកែ ៖ ណែនាំកែប្រែបុគ្គលិក ថែទាំដូចម្ដាយនិងកូន ដេរទៅហៅមក(ម៉ែគេ)

– មេគុក ៖ មើលការខុសត្រូវពីសុខទុក្ខនិងជីវភាពរស់នៅនិងនាំមុខរាល់កិច្ចការទាំងឡាយ(មុខគេ)

– វៀរចាកអគតិទាំង ៤

ឆន្ទាគតិ (លំអៀងព្រោះស្រឡាញ់)

ទោសាគតិ (លំអៀងព្រោះស្អប់)

មោហាគតិ (លំអៀងព្រោះល្ងង់)

ភយាគតិ (លំអៀងព្រោះភ័យ) (ពីង គិមឆេន ២០១៩)។

– មានព្រហ្មវិហារធម៌ ទាំងបួន មេត្តា ករុណា មុតិតា ឧបេក្ខា

– ភាពជាអ្នកដឹកនាំរបស់ព្រះនាងឥន្ទ្រទេវី *ទឹកអម្រែក ភ្នែកខ្លែង ស្នែងរាជសី សំដីឥសូរ ថ្ងូរព្រះឥន្ទ សុបិនសួគ៌ ខួរទន្សាយ សប្បាយស្រមោច* (កឹម អឿន ២០១៦)។

- **ការប្ដេជ្ញាចិត្ត**

– កសាងទំនុកចិត្តដល់អង្គភាព

– ហ៊ាននិយាយ ហ៊ានធ្វើ ហ៊ានទទួលខុសត្រូវ

– មានមនសិការខ្ពស់ក្នុងការដឹកនាំ

– មានយុត្តិធម៌ និងអព្យាក្រឹតក្នុងការដឹកនាំ

– មានគំនិតផ្ដួចផ្ដើម និងការច្នៃប្រឌិតខ្ពស់

– តស៊ូ អំណត់អត់ធន់ ព្យាយាមក្នុងការបំពេញភារកិច្ច

– ស្មោះត្រង់ និងទទួលខុសត្រូវលើការងាររបស់ខ្លួន និងអង្គភាពទាំងមូល

– ផ្ដល់ព័ត៌មានដល់បុគ្គលិក និងគ្រូទាំងអស់ឱ្យបានដូចគ្នា

- គោរពស្រឡាញ់អ្នកក្រោមឱវាទស្មើៗគ្នាដោយគោរពកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គលិក គ្រូ សិស្ស និងអ្នកក្រោមបង្គាប់ក្នុងពេលបំពេញការងារ
- រក្សាការសម្ងាត់ និងពត៌មានផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ
- មិនប្រព្រឹត្តអំពើពុករលួយ ឬស៊ីសំណូកសូកប៉ាន់ (នូវ រីរ៉ា ២០១៩)។

### ៣ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍

- មានចក្ខុវិស័យ បេសកកម្ម គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ
- ការអនុវត្តចក្ខុវិស័យ និងផែនការសកម្មភាព
- ការត្រួតពិនិត្យ និងវាយតម្លៃការងារ
- ដឹកនាំការអនុវត្តផែនការយុទ្ធសាស្ត្រសាលារៀន
- បង្ហាញពីទស្សនៈវិស័យសាលារៀន និងធ្វើជាគម្រូនៃតម្លៃការងារ និងការអនុវត្តប្រចាំថ្ងៃ
- ធ្វើការសម្រេចចិត្តដោយដូនដំណឹង
- ប្រើប្រាស់កស្តុតាងច្រើនផ្សេងៗគ្នា ដើម្បីគាំទ្រ ត្រួតពិនិត្យ វាយតម្លៃ និងកែលម្អផែនការយុទ្ធសាស្ត្រ
- អនុវត្តន៍ការពិនិត្យឡើងវិញជាប្រចាំនៃការអនុវត្តគម្រោង កម្មវិធី និងប្រើប្រាស់លទ្ធផល ក្នុងការណែនាំពីបញ្ហា និងការបារម្ភក្នុងការអនុវត្តផែនការ
- ដឹកនាំការផ្លាស់ប្តូរ និងការបង្កើតថ្មី
- ដឹកនាំដំណើរការផ្លាស់ប្តូរសំដៅទៅលើការអនុវត្ត និងអភិវឌ្ឍគោលវិធីប្រព័ន្ធរចនាសម្ព័ន្ធថ្មី
- ធ្វើឱ្យមាននិរន្តរភាពគំនិតច្នៃប្រឌិត និងការបង្កើតថ្មីនៅក្នុងកម្មវិធីសាលាដើម្បីសម្រេចបាននូវ លទ្ធផលសិក្សាខ្ពស់ជាងមុន (SEAMEO 2011)។

### ៤ ភាពជាអ្នកដឹកនាំ គ្រប់គ្រងរដ្ឋបាលសាលារៀន

- ការគ្រប់គ្រងរដ្ឋបាល និងបច្ចេកទេស
- ការគ្រប់គ្រងបុគ្គលិក
- ការគ្រប់គ្រងហិរញ្ញវត្ថុ។

## ៥ ភាពជាអ្នកដឹកនាំ លើកម្មវិធីសិក្សា ការបង្រៀន និងរៀន

- ការគ្រប់គ្រងការបង្រៀន និងរៀន
- ការសិក្សាស្រាវជ្រាវ
- ការសហការ និងកសាងទំនាក់ទំនង
- ការអភិវឌ្ឍសមត្ថភាព
- ការធ្វើអធិការកិច្ចផ្ទៃក្នុង
- ការដឹកនាំកែលម្អ និងការអនុវត្តកម្មវិធីសិក្សា
- ការគ្រប់គ្រងការអនុវត្តកម្មវិធីសិក្សា
- លើកកម្ពស់ការយល់ដឹង និងទទួលយកបាននូវការបង្រៀនប្រភេទផ្សេងៗគ្នា និងសម្បូរបែប
- ការបង្កើតបរិស្ថានសិក្សាតាមបែបសិស្សមជ្ឈមណ្ឌល
- លើកកម្ពស់បរិស្ថានសិក្សាដែលអាចរួមបញ្ចូល សុវត្ថិភាព និងសុខភាពល្អ
- លើកកម្ពស់វប្បធម៌សន្តិភាព និងការគោរពលក្ខណៈផ្សេងៗគ្នា
- គ្រប់គ្រង និងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន
- ដាក់ចេញនូវគំរូសមស្របមួយ លើការត្រួតពិនិត្យ និងវាយតម្លៃ
- ការផ្តល់នូវលទ្ធផលសិក្សាដែលបានគ្រោងទុក (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។

## ៦ ការផ្សារភ្ជាប់សាលារៀន និងសហគន៍

- អាជ្ញាធរដែនដី
- មាតាបិតាឬអាណាព្យាបាលសិស្ស
- ភាគីពាក់ព័ន្ធនានា
- លើកកម្ពស់ទំនួលខុសត្រូវដោយចែករំលែកគ្នាសម្រាប់ការកែលម្អសាលារៀន
- បង្កើតទំនុកចិត្ត និងដឹកនាំក្រុម/សហគមន៍សម្រាប់កែលម្អសាលារៀន និងដៃគូពាក់ព័ន្ធ
- ការពង្រឹងការចូលរួមពីសហគមន៍ ក្នុងាការលើកកម្ពស់ដំណើរការងាររបស់សាលារៀន

- ការគ្រង់គ្រងកិច្ចសហការ និងបណ្តាញអប់រំ
- កសាងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពខ្ពស់ជាមួយនឹងភាគីពាក់ព័ន្ធ
- សម្របសម្រួលភាពជាដៃគូ និងសកម្មភាពសាលារៀន និងសហគមន៍
- ជម្រុញការបង្កើតមតិរួមគ្នា
- គ្រប់គ្រងលើការខ្វែងគំនិតគ្នា និងអនុវត្តជំនាញចរចា
- ជំនាញសម្របសម្រួល ដោះស្រាយទំនាស់
- រក្សានិរន្តរភាពទំនាក់ទំនង និងសហប្រតិបត្តិការជាមួយ ភាគីពាក់ព័ន្ធ គាំទ្រកម្មវិធី និងគម្រោងដែលផ្តោតលើសហគមន៍ (SEAMEO 2011)។

## ២.៣ ការគ្រប់គ្រងគ្រូបង្រៀន

យោងតាមសេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀនលេខ៥៣ អយក.សណន របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៩ និងដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ចាប់ពីឆ្នាំសិក្សា ២០១៩-២០២០ ក្រសួង អប់រំ យុវជន និងកីឡាដាក់ចេញនូវវិធានការដូចខាងក្រោម៖

### ២.៣.១ ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំ

គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ។ នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាងឬស្មើ៣ថ្នាក់ រីឯចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យ និងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញ និងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌឱ្យទៅដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន។ គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅដែល

សាមីខ្លួនបានជ្រើសរើសដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ។ ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខណ្ឌបណ្តោះអាសន្ន ព្រមទាំងពិនិត្យស្នើគោលការណ៍ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់។

### ២.៣.២ ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

គ្រឹះស្ថានសិក្សានីមួយៗ ត្រូវធ្វើការវិភាគ និងព្យាករអំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជា ជំនាញឱ្យបានច្បាស់លាស់មុននឹងលើកសំណើសុំគ្រូបង្រៀនបន្ថែម រួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល។ ការវិភាគ និងព្យាករអំពីតម្រូវការធនធានមនុស្សត្រូវអនុលោមតាមសេចក្តីណែនាំលេខ២០ អយក.សណន ស្តីពី និយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ គ្រឹះស្ថានសិក្សានីមួយៗ ត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់គ្រូបង្រៀនដើម្បីធានាថា ការសុំផ្លាស់ចេញ មិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគត។ គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថា គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមកនឹងបំពេញនូវតម្រូវការធនធានមនុស្សសម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

### ២.៣.៣ ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ

ក្រសួងអប់រំ យុវជន និងកីឡាចាប់ផ្តើមបន្តអនុវត្តការជ្រើសរើសបុគ្គលិកដូចខាងក្រោម៖

- បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ
- បន្តប្រឡងជ្រើសរើសក្របខណ្ឌថ្មី ទៅតាមប្រភេទក្របខណ្ឌ មុខវិជ្ជាជំនាញ
- ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្តដាច់ស្រយាល

- បន្តប្រឡងជ្រើសរើសបញ្ចូលក្របខណ្ឌចំពោះបេក្ខជនដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- ការជ្រើសរើសគ្រូបន្ថែមគួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ហា ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំង កាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន
- ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ការប្រឡងជ្រើសរើសគ្រូក្របខណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើស ក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ការបែងចែកក្របខណ្ឌថ្មីសម្រាប់ការប្រឡងជ្រើសរើសត្រូវរៀបចំបែងចែកតាមដំណាក់កាល។

## ២.៣.៤ ការដោះស្រាយស្ថានភាពលើសម្ពុះគ្រូបង្រៀន

ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មីដូចខាងក្រោម៖

- ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានីខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍
- គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើសត្រូវទៅបម្រើការនៅទីនោះ
- បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច
- គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្សឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

### ២.៣.៥ សាលារៀនលើសគ្រូបង្រៀន

#### ករណីរាជធានីភ្នំពេញ

អនុវត្តសាកល្បងនៅរាជធានីភ្នំពេញ ដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀនដែល មានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

#### ករណីខេត្តផ្សេងទៀត

- បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
- ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
- សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

### ២.៣.៦ សាលារៀនខ្វះគ្រូបង្រៀន

- ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋម សិក្សាដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ
- ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ការស្នើបញ្ចូលក្របខណ្ឌ (ទាំងគ្រូក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា)ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាពនិងប្រសិទ្ធភាព។

**ការប្រើប្រាស់ប្រាក់ម៉ោងបន្ថែម (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០១៧)**

- ម៉ោងបន្ថែមសំដៅដល់ចំនួនម៉ោងដែលគ្រូបង្រៀនបានបង្រៀន និងបំពេញការងារគរុកោសល្យព្រមទាំងការងារ ពាក់ព័ន្ធនឹងការបង្រៀនលើសពីចំនួនម៉ោងកំណត់
- គ្រូបង្រៀន អាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើន បំផុត៤៨ម៉ោងក្នុង១ខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត
- មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុតចំនួន៣២ម៉ោងក្នុង១ខែ។

**គ្រឹះស្ថានសិក្សាសាធារណៈដែលអាចអនុវត្តរបបម៉ោងបន្ថែមបាន លុះត្រាតែ៖**

- បានគ្រោងឥណទានថវិកាសម្រាប់របបម៉ោងបន្ថែម
- ពុំមានគ្រូបង្រៀនគ្រប់គ្រាន់ ដើម្បីបង្រៀនមុខវិជ្ជាស្របតាមនិយាមកំណត់
- ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសាមី
- ប្រើប្រាស់របបម៉ោងបន្ថែមក្នុងវង្វង់ឥណទានថវិកាដែលផ្តល់ឱ្យតែប៉ុណ្ណោះ។

**អ្នកមានសិទ្ធិបង្រៀនម៉ោងបន្ថែម លុះត្រាតែ ៖**

- ជាមន្ត្រីរាជការជាគ្រូបង្រៀន ប្រចាំគ្រឹះស្ថានសិក្សា
- ជាមន្ត្រីរាជការមិនមែនជាគ្រូបង្រៀន ដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងគ្រឹះស្ថានសិក្សា
- មានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម
- ជាគ្រូបង្រៀនបានអនុវត្តពេញលេញការបង្រៀនតាមរបបម៉ោងកំណត់។

គ្រឹះស្ថានសិក្សាសាធារណៈ ដែលមានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់របស់ខ្លួនពីការបង់ថ្លៃរបស់សិស្ស សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗ សរុបលើសពី ៥០% នៃថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាតឱ្យមានការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិឡើយ។

**ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន**

- ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ
- អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិនហើយ ត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តដែលត្រូវផ្លាស់ចូលទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន
- អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌចេញក្រៅក្រសួងចំនួន៥០នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក
- មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស
- ការផ្លាស់ប្តូរពីរាជធានី ខេត្ត ចូលអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡងវាស់ស្ទង់សមត្ថភាព និងឆ្លងកាត់ការធ្វើសមាសន៍ដោយផ្ទាល់ពីប្រធានអង្គភាព ដែលត្រូវផ្លាស់ចូល។

**ការផ្លាស់ប្តូរតាមសហព័ទ្ធ**

- ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ)
- អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ទ្ធចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ
- គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរបន្ទាប់ពីសាមីខ្លួនបាន បញ្ចប់កម្មសិក្សាដោយជោគជ័យ។

## ២.៤ និយាមប្រើប្រាស់បុគ្គលិកអប់រំតាមនិយាមថ្មី

ដើម្បីធ្វើឱ្យប្រសើរឡើងលើការប្រើប្រាស់ និងការបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ ដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋបាលនិងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំប្រកបដោយគុណភាពស្របទៅនឹងបរិបទនៃការអប់រំបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា បានពិនិត្យនិងកែសម្រួលឡើងវិញ សេចក្តីណែនាំស្តីពីនិយាមប្រើបុគ្គលិកអប់រំ និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំសិក្សា២០១៨-២០១៩តទៅ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

### ២.៤.១ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ និងម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ

ក្នុងការកំណត់ប្រភេទគ្រឹះស្ថានមធ្យមសិក្សាសាធារណៈបើចំនួនថ្នាក់តិចជាងឬស្មើ ២០គឺចូលក្នុងប្រភេទសាលាតូច ថ្នាក់ចាប់ពី២១ដល់៤០គឺប្រភេទសាលាមធ្យម និងបើថ្នាក់ចាប់ពី៤១ថ្នាក់ឡើងគឺចាត់ជាសាលាធំ។

*តារាងទី 1៖ ការកំណត់ម៉ោងបំពេញកាងាររបស់បុគ្គលិកអប់រំ*

| ប្រភេទគ្រឹះស្ថានសិក្សាសាធាណៈ | ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ ក្នុងមួយសប្តាហ៍ | ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀន ឱ្យគ្រប់៤០ម៉ោងក្នុងមួយសប្តាហ៍ |
|---|---|---|
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |
| មធ្យមសិក្សាទុតិយភូមិ | ១៦ ម៉ោង | ២៤ ម៉ោង |

តារាងទី១បង្ហាញពីចំនួនម៉ោងបំពេញរបស់បុគ្គលិកអប់រំនៅមធ្យមសិក្សាបឋមភូមិដែលមាន១៨ម៉ោងនៅក្នុងថ្នាក់រៀនក្នុងមួយសប្តាហ៍និង២២ម៉ោងសម្រាប់គាំទ្រដល់ការបង្រៀន។ នៅមធ្យមសិក្សាទុតិយភូមិគឺមាន១៦ម៉ោងនៅក្នុងថ្នាក់រៀន ក្នុងមួយសប្តាហ៍ និង២៤ម៉ោងសម្រាប់គាំទ្រដល់ការបង្រៀន។ សរុបមកបុគ្គលិកម្នាក់ត្រូវបំពេញការងារ៤០ម៉ោងក្នុងមួយសប្តាហ៍។

*តារាងទី 2៖ ម៉ោងប្រចាំសប្តាហ៍សម្រាប់ការបង្រៀនក្នុងថ្នាក់ និងការបំពេញភារកិច្ចរបស់បុគ្គលិកអប់រំ*

| ល.រ | ភារកិច្ចដែលត្រូវបំពេញ | ចំនួនម៉ោងក្នុងមួយសប្តាហ៍ |
|---|---|---|
| ក | ម៉ោងកំណត់បង្រៀនសិស្ស/និស្សិតក្នុងថ្នាក់ | ១៨ |
| | ក.១ បង្រៀនសុទ្ធសាធ | ១៨ |
| | ក.២ បង្រៀន + ទទួលបន្ទុកថ្នាក់ | ១៤ |
| | ក.៣ បង្រៀន + ប្រធានក្រុមបច្ចេកទេស | ១៦ |
| | ក.៤ បង្រៀន + ទទួលបន្ទុកថ្នាក់ +ប្រធានក្រុមបច្ចេកទេស | ១២ |
| ខ | ម៉ោងបំពេញការងារគាំទ្រការបង្រៀន | ២២ |
| គ | ម៉ោងបំពេញការងាររបស់គ្រូទទួលបន្ទុកថ្នាក់ | ៤ |
| ឃ | ម៉ោងបំពេញការងាររបស់ប្រធានក្រុម បច្ចេកទេស | ២ |
| | **សរុប** | **៤០** |

តារាងទី២ បង្ហាញពីចំនួនម៉ោងដែលត្រូវបំពេញការងាររបស់បុគ្គលិកអប់រំ ទាំងការបង្រៀនក្នុងថ្នាក់ និងតាមបំណែងចែកតួនាទីភារកិច្ច។ បុគ្គលិកម្នាក់ៗត្រូវបង្រៀននិងបំពេញការងារ៤០ម៉ោងក្នុងមួយសប្តាហ៍។

### ២.៤.២ និយាមប្រើបុគ្គលិកអប់រំតាមគ្រឹះស្ថានសិក្សាសាធារណៈ

*តារាងទី 3៖ និយាមប្រើបុគ្គលិកបង្រៀន*

| គ្រឹះស្ថានសិក្សាសាធារណៈ | និយាមប្រើចំនួនគ្រូ-សិស្ស | |
|---|---|---|
| | និយាមថ្នាក់ - គ្រូបង្រៀន | ផលធៀប សិស្ស-ថ្នាក់ |
| មធ្យមសិក្សាបឋមភូមិ | ១ / ១.៨៣៣ | ៤០- ៥០ |

តារាងទី៣បង្ហាញពីនិយាមប្រើចំនួនគ្រូដែលត្រូវបង្រៀនក្នុងមួយថ្នាក់ និងចំនួនសិស្សដែលត្រូវដាក់ក្នុងមួយថ្នាក់នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ថ្នាក់រៀន១ត្រូវប្រើគ្រូ១.៨៣៣ និងថ្នាក់រៀន១ត្រូវមានសិស្ស៤០នាក់ទៅ៥០នាក់។

*តារាងទី 4៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀននៅមធ្យមសិក្សាចំណោះទូទៅ*

| តួនាទី និងភារកិច្ច | សាលាតូច តិចជាងឬស្មើ ២០ ថ្នាក់ | | | សាលាមធ្យម ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | | សាលាធំ ចាប់ពី ៤១ ថ្នាក់ឡើង | |
|---|---|---|---|---|---|---|---|
| | ៦ | ៧-១៤ | ១៥-២០ | ២១-២៩ | ៣០-៤០ | ៤១-៦០ | ៦១-៨០+ |
| នាយក | ១ | ១ | ១ | ១ | ១ | ១ | ១ |
| នាយករង | | ១ | ២ | ២ | ២ | ៣ | ៣ |
| លេខាធិការ | ១ | ១ | ១ | ១ | ២ | ២ | ២ |
| បណ្ណារក្ស | | ១ | ២ | ២ | ២ | ៣ | ៣ |
| បេឡា | | | | ១ | ១ | ១ | ១ |
| គណនេយ្យ | | ១ | ១ | ១ | ១ | ១ | ១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| អ្នកទទួលបន្ទុកយុវជន | | | ១ | ១ | ១ | ២ | ២ |
| អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍ (បើមានសម្ភារ និងដំណើរការ) | | ២ | ២ | ៣ | ៣ | ៣ | ៤ |
| បុគ្គលិក ឬឆ្មាំ | | | | | | | ២ |
| អន្តេវាសិកដ្ឋាន សិស្ស ៦០ នាក់ អ្នកគ្រប់គ្រង១នាក់ | | | | | | | |
| អ្នកដាំស្លសិស្ស៥០នាក់អ្នកដាំស្ល១នាក់ | | | | | | | |
| **សរុប** | ២ | ៧ | ១០ | ១២ | ១៣ | ១៦ | ១៩ |

តារាងទី៤បង្ហាញពីចំនួនបុគ្គលិកការិយាល័យដែលត្រូវបំពេញតាម តួនាទី ភារកិច្ចទៅតាមប្រភេទ សាលាតូច សាលាមធ្យម និងសាលាធំ។

## ២.៥ មុខវិជ្ជាសិក្សា និងម៉ោងសិក្សានៅមធ្យមសិក្សាបឋមភូមិ

### ក.សមត្ថភាពរំពឹងទុក

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិសិស្សនឹងទទួលបាន (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥)៖

**វិជ្ជាសម្បទា**

– មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌

- មានចំណេះដឹងមូលដ្ឋានគ្រឹះ ផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍(ICT) និងភាសាបរទេស។

**បំណិនសម្បទា**

- មានបំណិនមូលដ្ឋានរឹង និងទូលំទូលាយផ្នែក ភាសាខ្មែរ ( អំណាន ការសរសេរការនិយាយ និងការស្តាប់ )
- មានបំណិនមូលដ្ឋានរឹងមាំ ផ្នែកគណិតវិទ្យា (គណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះ-ស្រាយបញ្ហា )
- មានបំណិនប្រើប្រាស់ចំណេះដឹង ផ្នែកវិទ្យាសាស្រ្ត បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សា និងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទង ទូលំទូលាយ សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ
- មានបំណិនបង្ការ និងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ ។

**ចរិយាសម្បទា**

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ
- ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិតំបន់ និងអន្តរជាតិ
- ស្រឡាញ់និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្មនិងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុមទាំងក្នុងការសិក្សា និងការរស់នៅ ប្រចាំថ្ងៃ។

**មុខវិជ្ជា**

ភាសាខ្មែរ( សរសេរតាមអាន តែងសេចក្តី វេយ្យាករណ៍ មេសូត្រ សិក្សាអត្ថបទ ) គណិតវិទ្យា វិទ្យាសាស្ត្រ រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា សិក្សាសង្គម ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍(ICT) ភាសាបរទេស អប់រំសិល្បៈ អប់រំកាយនិងកីឡា អប់រំសុខភាព បំណិនជីវិតតាមមូលដ្ឋាន។

**ខ.ម៉ោងសិក្សា**

*តារាងទី 5៖ របាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី៧ ទី៨ និងទី៩*

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | **៧** | **៨** | **៩** |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍( ICT ) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ៣ | ៣ | ៣ |
| **សរុបម៉ោងសិក្សាប្រចាំសប្តាហ៍** | | **៤០** | **៤០** | **៤០** |

( ក្រសួងអប់រំ យុវជន និងកីឡា ២០១៥ )

សំគាល់ ៖ ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី ៤ ទៅ ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និងមួយម៉ោងសិក្សាមានរយៈពេល ៥០នាទី

*តារាងទី ៦៖ កម្មវិធីសិក្សាលម្អិត ផ្នែកមធ្យមសិក្សា*

| **ល.រ** | **មុខវិជ្ជាបង្រៀន** | **ចំនួនម៉ោងក្នុង ១ សប្តាហ៍** | **ផ្សេងៗ** |
|---|---|---|---|
| ១ | ភាសាខ្មែរ | **៧ម៉ោង**x៣៥សប្តាហ៍ = ២៤៥ម៉ោង /១ឆ្នាំសិក្សា | ❖ សរសេរតាមអាន<br>❖ តែងសេចក្តី<br>❖ វេយ្យាករណ៍<br>❖ មេសូត្រ<br>❖ សិក្សាអត្ថបទ |
| ២ | ភាសាបរទេស( បារាំង ) | **២ម៉ោង**x៣៥សប្តាហ៍ = ៧០ម៉ោង /១ឆ្នាំសិក្សា | |
| | ភាសាបរទេស( អង់គ្លេស ) | **៤ម៉ោង**x៣៥សប្តាហ៍ = ១៤០ម៉ោង /១ឆ្នាំសិក្សា | |
| ៣ | គណិតវិទ្យា | **៧ម៉ោង**x៣៥សប្តាហ៍ = ២៤៥ម៉ោង /១ឆ្នាំសិក្សា | ❖ នព្វន្ត<br>❖ រង្វាស់រង្វាល់<br>❖ ធរណីមាត្រ<br>❖ ស្ថិតិ<br>❖ ប្រូបាបប៊ីលិតេ<br>❖ ពីជគណិត |
| ៤ | រូបវិទ្យា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ៥ | គីមីវិទ្យា | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | |

| | | | |
|---|---|---|---|
| ៦ | ជីវៈវិទ្យា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | |
| ៨ | ប្រវត្តិវិទ្យា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ៩ | ភូមិវិទ្យា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ១០ | សីលធម៌-ពលរដ្ឋវិជ្ជា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ១១ | គេហសេដ្ឋកិច្ចវិទ្យា | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | ❖ សណ្តាប់ធ្នាប់ ការសន្សំសំចៃ និងសោភ័ណភាព<br>❖ ផលិតផលជាស្នាដៃខ្ញុំ<br>❖ មនុស្ស និងអាជីព<br>❖ អាជីវករ និង កិត្តិនាមក្នុងអាជីវកម្ម<br>❖ សហគ្រិនភាព<br>❖ ដំណើរការរបស់សហគ្រាស |
| ១២ | បច្ចេកទេសវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |
| ១៣ | អប់រំកាយនិងកីឡា | **២ម៉ោង** x ៣៥សប្តាហ៍ = ៧០ម៉ោង/១ឆ្នាំសិក្សា | |

| | | | |
|---|---|---|---|
| ១៤ | អប់រំសិល្បៈ | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | ❖ តន្ត្រី<br>❖ ចម្រៀង<br>❖ ការលេងឧបករណ៍តន្ត្រី<br>❖ របាំ<br>❖ គំនូរ<br>❖ ហត្ថកម្ម<br>❖ ការផ្តល់គុណតម្លៃ<br>❖ ល្បែងសិក្សាតន្ត្រី |
| ១៥ | អប់រំសុខភាព | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | ❖ សុខភាពបឋម<br>❖ សុខភាពផ្លូវចិត្ត<br>❖ សុខភាពបន្តពូជ និងផ្លូវភេទ<br>❖ សុខភាព និងបរិស្ថាន<br>❖ សុខភាព និងជំនឿ |
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | **១ម៉ោង** x ៣៥សប្តាហ៍ = ៣៥ម៉ោង/១ឆ្នាំសិក្សា | ❖ កសិកម្ម<br>❖ សេវាកម្ម<br>❖ សិប្បកម្ម<br>❖ សហគ្រិនភាព និងភាពជាអ្នកដឹកនាំ<br>❖ បញ្ហាសង្គម |

## ២.៦ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា

តាមរយៈឯកសារទស្សនវិជ្ជានៃការអប់រំ ច្បាប់អប់រំ និងគោលនយោបាយអប់រំរបស់ឯកឧត្តមបណ្ឌិត ស៊ន សេងហុកក្រោយពីបានសិក្សាទស្សនវិជ្ជាអប់រំ បូរាណសម័យ សម័យបួនភព និងសហសម័យ យើងបានពិចារណា ទៅលើបញ្ហានៃការអប់រំនៅកម្ពុជា តាមរយៈវិធីទស្សនវិជ្ជាជាវិធីមួយដែលគេបង្កើតឡើងសម្រាប់ធ្វើការឆ្លុះបញ្ចាំងអំពី បញ្ហាផ្សេងៗក្នុងគោលបំណងស្វែងរកសច្ចភាពដើម្បីលើកជាយុទ្ធសា-ស្ត្រដោះស្រាយបញ្ហា។ វិធីទស្សនវិជ្ជាទាំងនោះរួមមាន៧ជំហានគឺ៖

- ជំហានទី១: កំណត់បញ្ហា
- ជំហានទី២: វិភាគបញ្ហា
- ជំហានទី៣: កំណត់លក្ខណៈវិនិច្ឆ័យដំណោះស្រាយឱ្យបានល្អបំផុត
- ជំហានទី៤: ស្នើដំណោះស្រាយ
- ជំហានទី៥: វាយតម្លៃដំណោះស្រាយ
- ជំហានទី៦: ជ្រើសរើសដំណោះស្រាយ
- ជំហានទី៧: លើកយុទ្ធសាស្ត្រអនុវត្តដំណោះស្រាយ។

ដូចនេះ តាមការពិចារណា តាមវិធីទស្សនវិជ្ជាខាងលើ យើងរកឃើញបញ្ហាអប់រំនៅគ្រឹះស្ថានសិក្សាមួយចំនួនដូចខាងក្រោម៖

### ២.៦.១ បញ្ហាប្រឈមពាក់ព័ន្ធគ្រឹះស្ថានសិក្សា

តាមការសង្កេត និងការត្រួតពិនិត្យនៅតាមសាលារៀន ព្រមទាំងការផ្តល់បទសម្ភាសពីនិស្សិតវគ្គនាយកក្នុងឆ្នាំសិក្សា២០១៨ និងឆ្នាំ២០១៩ ដែលទទួលបានការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ បានរកឃើញបញ្ហាប្រឈមនៃការអប់រំតាមសាលាវិទ្យាល័យ និងអនុវិទ្យាល័យមួយចំនួនដូចខាងក្រោម (ស៊ន សេងហុក ២០១៩)៖

**ក.បញ្ហាប្រឈមពាក់ព័ន្ធការសិក្សារបស់សិស្សមាន៖**

- សិស្សមិនចង់រៀន និងធ្លាក់មធ្យមភាគច្រើន
- សិស្សមិនខិតខំរៀនសូត្រ ភ្លើតភ្លើនតាមសម្ភារនិយម
- ការគ្រប់គ្រងវិន័យសិស្សមានការធ្លាក់ចុះ
- ការសេពគប់មជ្ឈដ្ឋានខាងក្រៅ (គ្រឿងញៀន...)
- សិស្សមិនមានទំនួលខុសត្រូវក្នុងកិច្ចការសាលារបស់ខ្លួន

- សិស្សអវត្តមានច្រើន(ជួយធ្វើការឪពុក ម្តាយ ជួយរកកម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ)
- សិស្សបោះបង់ការសិក្សាច្រើន(រៀបការ ចំណាកស្រុក ធ្វើការរោងចក្រ សំណង់.....)
- សិស្សទី៦ ឡើងទី៧ ខ្សោយអំណាន សំណេរ និងគណិតវិទ្យា
- តំបន់ជនបទ និងដាច់ស្រយាលខ្វះផ្ទះគ្រូ(គ្រូមួយចំនួនមានទីលំនៅឆ្ងាយ)។

**ខ.បញ្ហាប្រឈមពាក់ព័ន្ធការបំពេញភារៈកិច្ចរបស់គ្រូបង្រៀន ៖**

- មិនមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រង
- មិនបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ
- មិនគោរពពេលវេលា
- គ្រូមួយចំនួនបង្រៀនសិស្សគ្មានកិច្ចតែងការ
- វិន័យធូររលង់
- គ្មានយុទ្ធសាស្ត្រក្នុងការទប់ស្កាត់សិស្សរៀនយឺត
- មិនមានការស្រាវជ្រាវបន្ថែម គ្មានគំនិតច្នៃប្រឌិត ផ្អត់គំនិតនៅបុរាណ
- បង្រៀនពីរពេល មិនសូវមានពេលទំនេរដើម្បីស្រាវជ្រាវ
- គ្មានមនសិការវិជ្ជាជីវៈ មិនយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្ស ។

**គ. បញ្ហាប្រឈមពាក់ព័ន្ធនឹងសាលារៀន**

- គ្មានសម្ភារឧបទ្ទេសគ្រប់គ្រាន់ សម្រាប់ដំណើរការបង្រៀន និងរៀន
- សិស្សច្រើន លើសនិយាម
- បរិស្ថានមិនស្អាត គ្មានភាពទាក់ទាញ
- ខ្វះបង្គន់អនាម័យ ឬបង្គន់ប្រើមិនបាន
- ខ្វះស្វ័យវាយតម្លៃ នាយកសាលាមិនបានអនុវត្តតួនាទីជាអធិការអចិន្ត្រៃយ៍

- សហគមន៏មិនចូលរួម។
- ខ្វះគ្រូបង្រៀនពិសេសគ្រូទុតិយភូមិនៅសាលាជនបទ( សាលាខ្លះគ្រូលើសតែឯកទេសមួយចំនួនខ្វះគ្រូ)
- ខ្វះអគារសិក្សា ខ្វះបន្ទប់រៀន អាគារសិក្សាមួយចំនួនមានសភាពទ្រុឌទ្រោម
- ខ្វះសៀវភៅគ្រូ និងឯកសារស្រាវជ្រាវ
- ខ្វះសៀវភៅ និងគ្រូបំណិនជីវិត (រោងជាង កសិកម្ម សិល្បៈ កុំព្យូទ័រ)
- បណ្ណារក្សភាគច្រើនមិនបានឆ្លងកាត់វគ្គបំប៉នការងារបណ្ណាល័យ
- ខ្វះបណ្ណាល័យ ខ្វះសៀវភៅ និងឯកសារស្រាវជ្រាវ( ក្នុងបណ្ណាល័យ)
- ខ្វះបង្គន់អនាម័យ និងប្រភពទឹកប្រើប្រាស់
- ការចូលរួមរបស់សហគមន៍មួយចំនួននៅមានកម្រិត
- អាណាព្យាបាលសិស្សមួយចំនួនធំមិនយកចិត្តទុកដាក់ និងតាមដានការសិក្សារបស់កូនៗ
- ខ្វះបន្ទប់ពិសោធន៍ សម្ភារៈពិសោធន៍ និងខ្វះគ្រូពិសោធន៍
- ចំនួនសិស្សអាហារូបករណ៍ក្រីក្ររៀនពូកែមានចំនួនតិចបើប្រៀបធៀបនឹង សិស្សក្រីក្រ មានចំនួនច្រើន
- ការងាររដ្ឋបាល និងគណនេយ្យមិនទាន់មានដំណើរការល្អ (គ្រូខ្វះចំណេះដឹងផ្នែកកុំព្យូទ័រគ្រូមិនចូលចិត្តធ្វើការងារទាំងនេះ ផ្លាស់ប្តូរញឹកញាប់)
- នាយក នាយករង គ្រូបង្រៀនសាលារៀនមួយចំនួនធ្វើការមិនសូវឯកភាពគ្នា។

### ២.៦.២ ឫសគល់នៃបញ្ហាក្នុងការអប់រំនៅកម្ពុជា

ផ្អែកតាមការស្រាវជ្រាវ និងតាមវិធីសាស្រ្តទស្សនវិជ្ជា យើងរកឃើញបញ្ហាដូចខាងលើ។ ដើម្បីដោះស្រាយបញ្ហាខាងលើ យើងត្រូវសិក្សាអំពីឫសគល់នៃបញ្ហាចំនួន៤ដែលពាក់ព័ន្ធនឹងការផ្តល់សេវាអប់រំនៅសាលាមធ្យមសិក្សាជាមុនសិន (ស៊ន សេងហុក ២០១៩)៖

**សេវានៅក្នុងសាលារៀនមានមិនគ្រប់**

ការផ្តល់សេវាអប់រំនៅតាមសាលាមធ្យមសិក្សាមួយ ចំនួនមានភាពខ្វះចន្លោះ និងមិនបានគ្រប់គ្រាន់ទេ ដូចជា បណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់អនាម័យ កន្លែង លេង ការអប់រំកាយ និងកីឡា សិល្បៈ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់ប្រឹក្សាយោបល់ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង ស្របតាមកម្មវិធីសិក្សា។

**សេវានៅក្នុងសាលារៀនមិនដំណើការ**

សេវាមួយចំនួនក្នុងសាលារៀនមធ្យមសិក្សាមិនដំណើរការ ដូចជាបណ្ណាល័យ បន្ទប់ពិសោធន៍ បន្ទប់អនាម័យ កន្លែងលេង ការអប់រំកាយ និងកីឡា សិល្បៈ គណៈកម្មការទ្រទ្រង់សាលារៀន ក្រុមប្រឹក្សាកុមារ ក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាវិន័យ ក្រុមប្រឹក្សាបច្ចេកទេស បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង ស្របតាមកម្មវិធីសិក្សា។

**សេវានៅក្នុងសាលារៀនមិនឆ្លើយតបនឹងតម្រូវការ**

សេវាអប់រំនៅសាលារៀនមធ្យមសិក្សា មួយចំនួនមិនឆ្លើយតបទៅនឹងអ្នកពាក់ព័ន្ធដូចជា៖ សេវាផ្តល់ព័ត៌មានអប់រំមិនបានឆ្លើយតបទៅអាណា ព្យាបាល សេវាមួយចំនួនមិនឆ្លើយតបនឹងតម្រូវការរបស់សិស្ស ដូចជា សេវាផ្តល់ប្រឹក្សា បណ្ណាល័យ បន្ទប់ ពិសោធន៍ បន្ទប់អនាម័យ កន្លែងលេង ការអប់រំកាយ និងកីឡា និងសិល្បៈ។

**ខ្វះការវាយតម្លៃ និងកែលម្អសេវា**

នាយកសាលាខ្វះការវាយតម្លៃ និងកែលម្អសេវា សាលារៀន ឱ្យមានដំណើរការរលូន និងប្រកបដោយចីរភាព។

### ២.៦.៣ ដំណោះស្រាយបញ្ហាប្រឈមនៃការអប់រំនៅគ្រឹះស្ថានមធ្យមសិក្សា

ដើម្បីដោះស្រាយបញ្ហាខាង លើត្រូវរំលើងឫសគល់នៃបញ្ហាទាំងនោះជាមុនសិន។ ដើម្បីឱ្យសេវានៅក្នុងសាលារៀនមានគ្រប់ ហើយដំណើរការ សេវានៅក្នុងសាលារៀនឆ្លើយតបនឹងតម្រូវការ មានការវាយតម្លៃ និងកែលម្អសេវា ដែលជាឫសគល់ នាយកសាលា គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវអនុវត្តតាមយុទ្ធសាស្ត្រ ដែលជាគោលការណ៍អភិបាលកិច្ចល្អសាលារៀនរួមមាន (ស៊ន សេងហុក ២០១៩)៖

**ការចូលរួម៖** ការសម្រេចចិត្តធ្វើអ្វីមួយ ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធជាមុនសិន។ គ្រប់សកម្មភាព និងគ្រប់សេវាទាំងអស់ក្នុងសាលារៀន នាយកសាលាត្រូវកៀរគរ បញ្ចុះបញ្ចូល លើកទឹកចិត្តអ្នក

ពាក់ព័ន្ធមាន គ្រូបង្រៀន សិស្ស មាតាបិតា ឬអ្នកអាណាព្យាបាលរបស់សិស្ស សហគមន៍ អាជ្ញាធរ ឱ្យចូលរួមពាក់ព័ន្ធការកសាងផែនការអភិវឌ្ឍន៍សាលា ការផ្តល់សេវាអប់រំ ដូចជា សេវារៀន និងបង្រៀន បណ្ណាល័យ អប់រំកាយនិងកីឡា សិល្បៈ បន្ទប់ទឹក បរិស្ថាន សន្តិសុខ... ។

**ការគោរពច្បាប់៖** គ្រប់ការសម្រេចចិត្តធ្វើ សកម្មភាពដើម្បីផ្តល់សេវាអប់រំ នាយកសាលាត្រូវពិនិត្យមើលទៅលើគោលការណ៍ច្បាប់ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបច្ចេកទេសគ្រប់គ្រងបុគ្គលិក គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ គ្រប់គ្រងសិស្ស។ លើសពីនេះគ្រប់ការសម្រេចចិត្តក៏ត្រូវពិនិត្យ និងពិចារណាមើលគោលនយោបាយអប់រំ ដែលជាផែនទី បង្ហាញផ្លូវ សម្រាប់អនុវត្តលើការងារអប់រំ។

**តម្លាភាព៖** នាយកសាលា/គណៈគ្រប់គ្រង ត្រូវធ្វើការបិទផ្សាយ ចែកផ្សាយ និងផ្សព្វផ្សាយរាល់ការសម្រេចចិត្តក្នុងការអនុវត្តសកម្មភាពណាមួយ ដែលគាំទ្រសេវាតម្រូវការរបស់សិស្ស។ លើសពីនេះទៀត នាយកសាលាត្រូវបែងចែកការងារ និងធ្វើការជាក្រុមសម្រាប់អភិវឌ្ឍន៍សាលារៀន។

**ការព្រមព្រៀង និងឯកភាព៖** លទ្ធផលនៃការសម្រេចចិត្តត្រូវមានការព្រមព្រៀង និងឯកភាព តាមបែបប្រជាធិបតេយ្យ ដោយអនុវត្តតាមមតិភាគច្រើន ដោយស្របតាមគោលការណ៍ច្បាប់ និងក្របខណ្ឌគោលនយោបាយ។

**គណនេយ្យភាព៖** គឺជាបិតានៃការទទួលខុសត្រូវ។ នាយកសាលា/គណៈគ្រប់គ្រង ត្រូវបែងចែក ឱ្យមានការទទួលខុសត្រូវតាមលំដាប់ថ្នាក់ប្រជុំត្រួតពិនិត្យតាមដានរាល់គ្រប់សកម្មភាពការងារ ដែលបានចាត់ចែង ហើយនាយកត្រូវមានខ្សែគណនេយ្យភាពចំពោះការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា និងមានខ្សែគណនេយ្យភាពចំពោះថ្នាក់ក្រោម និងប្រជាពលរដ្ឋ។

**ប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ៖** គ្រប់ការបែងចែក ការចាត់ចែងទាំងអស់ ត្រូវធ្វើ ហើយធ្វើឱ្យត្រូវធ្វើឱ្យលឿន ធ្វើឱ្យអស់ថវិកាតិច។

**ភាពឆ្លើយតប៖** គ្រប់សេវាទាំងអស់ ត្រូវរៀបចំឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ។ តែព័ត៌មានអប់រំត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ឱពុកម្តាយឬអ្នកអាណាព្យាបាល។

**បរិយាបន្ន៖** គ្រប់សេវានៅក្នុងសាលារៀន ត្រូវដាក់បញ្ចូលសកម្មភាពប្រកបដោយសមធម៌។

សរុបសេចក្តីមក ដើម្បីដោះស្រាយបញ្ហា ត្រូវដោះតាមយុទ្ធសាស្ត្រ៨ចំណុចខាងលើ ដែលជាគោលការណ៍អភិបាលកិច្ចល្អក្នុងសាលារៀន។ ជាពិសេសការដោះស្រាយ ត្រូវផ្អែកតាមគោលនយោបាយ និងច្បាប់។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ គម្រោងវិភាគ

អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបចម្រុះមានទាំងបែបបរិមាណវិស័យ និងបែបគុណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់បិទ និងទម្រង់បើកដើម្បីប្រមូលទិន្នន័យពីគណៈគ្រប់គ្រងនៅតាមអនុវិទ្យាល័យចំនួន៤២ និងវិទ្យាល័យចំនួន២០ ក្នុងខេត្តបន្ទាយមានជ័យ។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ គឺសម្រាប់បំពេញដោយគណៈគ្រប់គ្រងសាលារៀន៖ នាយក /នាយិកា។

## ៣.២ ការប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលចេញដោយនាយកវិទ្យាស្ថានជាតិអប់រំទៅសុំការអនុញ្ញាតពីមន្ទីរអប់រំយុវជននិងកីឡាខេត្តបន្ទាយមានជ័យ ដើម្បីចុះប្រមូលទិន្ន័យនៅតាមសាលារៀនគោលដៅ។ ដោយពេលវេលានៃការស្រាវជ្រាវមានរយៈពេលខ្លី អ្នកស្រាវជ្រាវបានទាក់ទងទៅនាយកសាលានីមួយៗដោយផ្ទាល់ផង និងតាមទូរសព្ទ ដើម្បីសុំការអនុញ្ញាតពីគាត់ក្នុងការប្រមូលទិន្នន័យ។ អ្នកស្រាវជ្រាវបានស្កេន(Scan)លិខិតឧទ្ទេសនាមរួចផ្ញើជូននាយកសាលាមធ្យមសិក្សាទាំងអស់ដែលត្រូវប្រមូលទិន្នន័យតាមប្រព័ន្ធTelegramរួមទាំងកម្រងសំណួរសម្រាប់ធ្វើសម្ភាសន៍គាត់ផងដែរ ។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះអ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ កម្រងសំណួរនេះគឺសម្រាប់តែគណៈគ្រប់គ្រងសាលា៖នាយក/នាយិកា។

ក្នុងកម្រងសំណួរចែកចេញជា៥ផ្នែកគឺ៖ ផ្នែក"ក"៖ ព័ត៌មានទូទៅដែលជាប្រភេទសំណួរជ្រើសរើសមាន៦សំណួរមានដូចជា៖ ភេទ រយៈពេលបំពេញការងារជានាយក/នាយករង ឈ្មោះសាលា បង្រៀនម៉ោងបន្ថែម ចំនួនវេនបង្រៀន និងទីតាំងស្ថិតក្នុងស្រុកក្រុងនីមួយៗ។ ផ្នែក"ខ"៖ ការកំណត់ពីតម្រូវការដែលជាប្រភេ

បំពេញចទន្លោះ១សំណួរ និងបំពេញតារាង១សំណួរ ។ អ្នកស្រាវជ្រាវចង់បាន ចំនួនសិស្ស ចំនួនថ្នាក់តាមថ្នាក់ទី៧ទី៨និងទី៩ និងចង់បានទិន្នន័យចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌខ) ដែលមានតួនាទីជាគ្រូបង្រៀនឈរថ្នាក់តាមឯកទេសទាំង១៦ ដោយមិនគិតបុគ្គលិកការិយាល័យ។ ផ្នែក"គ"៖ទស្សនៈរបស់គណៈគ្រប់គ្រងលើការប្រើប្រាស់គ្រូបង្រៀន ជាប្រភេទដាក់កម្រិតលេខដែលមាន៥សំណួរ។ កម្រិតទាំងនោះគឺ៖ លេខ១ស្មើមធ្យម លេខ២ស្មើល្អបង្គួរ និងលេខ៣ស្មើល្អ។ ផ្នែក"ឃ"៖បញ្ហាប្រឈម និងដំណោះស្រាយ ជាសំណួរបើកដែលមាន២សំណួរ។ សំណួរនេះនាយក នាយិកាសាលានឹងលើកឡើងពីបញ្ហាប្រឈមនានា និងសំដោះស្រាយក្នុងការបែងចែក និងប្រើប្រាស់គ្រូបង្រៀនទៅតាមតួនាទី ភារកិច្ច។ ផ្នែកទី៥"ង"៖ មតិយោបល់បន្ថែមជាប្រភេទសំណួរបើកដែរដែលមាន១សំណួរ។ ត្រង់ផ្នែកនេះនាយក នាយិកាផ្តល់យោបល់ ឬសំណូមពរបន្ថែមទៅលើការប្រើប្រាស់គ្រូបង្រៀន។

ចំណែក នាយករង នាយិការង និងគ្រូបង្រៀន អ្នកស្រាវជ្រាវមិនបានសម្ភាសទេ ព្រោះចំនួនសាលាដែលគោលដៅដែលត្រូវធ្វើការស្រាវជ្រាវមានចំនួនច្រើន រីឯពេលវេលាមិនសូវគ្រប់គ្រាន់ រួមផ្សំជាមួយនឹងវិបត្តិ ជម្ងឺ Covid -19 និងគ្រោះទឹកជំនន់ផង។ កម្រងសំណួរនេះត្រូវបានបង្កើតឡើងដោយផ្អែក លើទ្រឹស្តីនានាទាក់ទង នឹងនិយាមប្រើប្រាស់គ្រូបង្រៀមានដូចជា សេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកសិក្សាថ្មី ស្តង់ដានាយកសាលារៀន សៀវភៅការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំ និងសំណួរមួយចំនួនទៀត។ កម្រងសំណួរខ្លះត្រូវបានបង្កើតតាមប្រព័ន្ធអនឡាញ ដោយប្រើប្រាស់ Google Form រួចផ្ញើជូននាយកសាលាតាម Telegram ។ តែចំពោះសាលាដែលមិនអាចឆ្លើយតាមប្រព័ន្ធអនឡាញ (online) អ្នកស្រាវជ្រាវចុះទៅធ្វើសម្ភាសប្រមូលទិន្នន័យដោយផ្ទាល់តាមទូរសព្ទ និងដោយផ្ទាល់។

## កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតប ក្នុងកម្រិតដាក់លាក់។ កម្រិតចង្អុលបង្ហាញ អាចបំពេញតាមអនឡាញឬគូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើគឺមានកម្រិតចង្អុលបង្ហាញចំនួន៣កម្រិត។ តួលេខចង្អុលបង្ហាញតាមបែប Likert Scale គឺគេនិយមចូល

ចិត្តប្រើច្រើនលើនិក្ខេបបទស្រាវជ្រាវក្នុងវិស័យអប់រំ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃទៅលើកម្រិតនៃការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនរបស់គណៈគ្រប់គ្រងសាលារៀន។

ក្នុងការសិក្សាស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរមាន៣កម្រិតពីទាបទៅខ្ពស់។ រូបមន្តនៃកម្រិតមានដូចខាងក្រោម៖

១ គឺ អនុវត្តបានកម្រិតមធ្យម

២ គឺ អនុវត្តបានកម្រិតល្អបង្គួរ

៣ គឺ អនុវត្តបានកម្រិតល្អ

ការបកស្រាយទៅលើការគណនាពិន្ទុពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្តដូចខាងក្រោម (Best 1981)៖

$$\frac{Highest\ Score - Lowest\ Score}{Number\ of\ Level} = \frac{3-1}{3} = 0.67$$

*តារាងទី 7៖ កម្រិតចង្អុលបង្ហាញ*

| | | |
|---|---|---|
| 1 – 1.67 | មានន័យថា | មធ្យម |
| 1.68 – 2.34 | មានន័យថា | ល្អបង្គួរ |
| 2.35 – 3 | មានន័យថា | ល្អ |

## ៣.៤ ការជ្រើសរើសគោលដៅ

### ទីតាំងភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ

ខេត្តបន្ទាយមានជ័យជាខេត្តមួយនៃព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅចុងពាយ័ព្យនៃប្រទេស។ ខេត្តនេះមានព្រំខេត្តជាប់ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប នៅខាងកើតខេត្តបាត់ដំបង នៅខាងត្បូង និងមានព្រំដែនរួមអន្តរជាតិជាមួយប្រទេសថៃនៅខាងលិច។ ទីរួមខេត្តនិងទីក្រុងធំបង្អស់គឺក្រុងសិរីសោភ័ណ និងក្រុងក្រុងប៉ោយប៉ែត។




ទូទាំងខេត្តបន្ទាយមានជ័យមានក្រុង២ និងស្រុក៧ ដែលវិទ្យាល័យចំនួន៣០ និងអនុវិទ្យាល័យចំនួន៥៤ក្នុងឆ្នាំសិក្សា ២០១៩-២០២០។

អ្នកស្រាវជ្រាវជ្រើសរើសយកសំណាក ចំនួន២០វិទ្យាល័យ និង៤២អនុវិទ្យាល័យក្នុងចំណោមស្រុក៧ក្រុង២ ដើម្បីប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវទាក់ទងទស្សនៈយល់ឃើញរបស់នាយក/នាយិកាទៅលើការប្រើប្រាស់គ្រូបង្រៀន ព្រោះរយៈពេលនៃការស្រាវជ្រាវមិនគ្រប់គ្រាន់ ជួបវិបត្តិជំងឺ Covid-19 និងគ្រោះទឹកជំនន់ផង។ ដោយឡែកអ្នកស្រាវជ្រាវបានប្រមូល ចំនួនសិស្ស ចំនួនថ្នាក់រៀន ចំនួនគ្រូកម្រិតមូលដ្ឋានបានគ្រប់ចំនួនសាលាទាំង៨៤ នៅតាមការិយាល័យអប់រំស្រុកក្រុង ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល ការិយាល័យផែនការនិងស្ថិតិ និងការិយាល័យមធ្យមសិក្សា។

អ្នកស្រាវជ្រាវកំណត់យកនាយក/នាយិកាសាលាតែ៦២នាក់ ដើម្បីធ្វើសម្ភាស និងបំពេញកម្រងសំណួរព្រោះពួកគាត់ជាអ្នកដែលអនុវត្តផ្ទាល់លើការប្រើប្រាស់គ្រូបង្រៀននៅក្នុងសាលា។

*តារាងទី ៥៖ ចំនួនសំណាកដែលត្រូវជ្រើសរើសសាលាក្នុងខេត្តបន្ទាយមានជ័យ*

| ល.រ | ឈ្មោះសាលា | ទីតាំងសាលារៀន | គណៈគ្រប់គ្រង |
|---|---|---|---|
| ១ | វិ.មង្គលបូរី | ស្រុក មង្គលបូរី | ១ |
| ២ | វិ.ហ៊ុន សែន មង្គលបូរី | | |
| ៣ | វិ.ភ្នំធំ | | ១ |
| ៤ | វិ.ពោងគោ | | |
| ៥ | វិ.ហ៊ុន សែន សំបួរ | | |
| ៦ | អនុវិ. រហាត់ទឹក | | ១ |
| ៧ | អនុវិ.សឿ | | ១ |
| ៨ | អនុវិ. បត់ត្រង់ | | ១ |
| ៩ | អនុវិ.ស្រះរាំង | | ១ |
| ១០ | អនុវិ.គយម៉ែង | | |
| ១១ | អនុវិ.តាអន | | |

| | | | |
|---|---|---|---|
| ១២ | អនុវិ.ឃិឡិ | | ១ |
| ១៣ | អនុវិ.សុវណ្ណគិរី | | ១ |
| ១៤ | អនុវិ.តាឡុំ | | ១ |
| ១៥ | អនុវិ.អូរស្វួត | | |
| ១៥ | វិ.ភ្នំស្រុក | ស្រុក ភ្នំស្រុក | ១ |
| ១៧ | វិ.ស.អ ប៉ោយចារ | | ១ |
| ១៨ | វិ.ណាំតៅ | | |
| ១៩ | អនុវិ.តាវង | | ១ |
| ២០ | អនុវិ.បុផ្ផាប្រសិទ្ធ | | ១ |
| ២១ | អនុវិ.កំពីងពួយ | | |
| ២២ | អនុវិ.ស្ពានមេត្រី | | ១ |
| ២៣ | វិ.បុស្សូវ | ស្រុក ព្រះនេត្រព្រះ | |
| ២៤ | វិ.ហស.ឈ្នួរមានជ័យ | | |
| ២៥ | វិ.ជប់វ៉ារី | | ១ |
| ២៦ | វិ.រហាល | | |
| ២៧ | វិ.ទឹកជោរ | | ១ |
| ២៨ | អនុវិ.ព្រះនេត្រព្រះ | | ១ |
| ២៩ | អនុវិ.ភ្នំលៀប | | ១ |
| ៣០ | អនុវិ.ប្រាសាទ | | |
| ៣១ | អនុ.ទានកាំ | | ១ |
| ៣២ | អនុវិ.រំដួល | | |
| ៣៣ | វិ.គូប | ស្រុក អូរជ្រៅ | ១ |
| ៣៤ | វិ.យាងដង្កុំ | | |

| | | | |
|---|---|---|---|
| ៣៥ | អនុវិ.កូនត្រី | | ១ |
| ៣៦ | អនុវិ.គូបតូច | | ១ |
| ៣៧ | អនុវិ.សូភី | | ១ |
| ៣៨ | អនុវិ.សំរោងមានជ័យ | | ១ |
| ៣៩ | អនុវិ.ឈូក | | |
| ៤០ | អនុវិ.សិង្គ | | ១ |
| ៤១ | វិ.សម្តេចឪ | | |
| ៤២ | វិ.ហស.ភ្លាកូន | | ១ |
| ៤៣ | វិ.អូរអំបិល | | ១ |
| ៤៤ | វិ.សិរីសោភ័ណ | | ១ |
| ៤៥ | អនុវិ.ទឹកថ្លា | ក្រុង សិរីសោភ័ណ | ១ |
| ៤៦ | អនុវិ.កំពង់ស្វាយ | | ១ |
| ៤៧ | អនុវិ.ភ្នៀត | | |
| ៤៨ | អនុវិ.ម្កាក់ | | |
| ៤៩ | អនុវិ.សែសិន | | |
| ៥០ | អនុវិ.អង្គារបុស្ស | | ១ |
| ៥១ | វិ.ថ្មពួក | | ១ |
| ៥២ | វិ.បន្ទាយឆ្មារ | | ១ |
| ៥៣ | អនុវិ.ភូមិថ្មី | | ១ |
| ៥៤ | អនុវិ.តាយឹងព្រៃវែង | ស្រុក ថ្មពួក | |
| ៥៥ | អនុវិ.គោករមៀត | | ១ |
| ៥៦ | អនុវិ.បន្ទាយមានឫទ្ធ | | ១ |
| ៥៧ | អនុវិ.ថ្មរមៀល | | |

| | | | |
|---|---|---|---|
| ៥៨ | អនុវិ.គោកកបិន | | ១ |
| ៥៩ | វិ.ស្វាយចេក | ស្រុក ស្វាយចេក | ១ |
| ៦០ | វិ.ផ្គាំ | | ១ |
| ៦១ | អនុវិ.ខ្វាវលិច | | |
| ៦២ | អនុវិ.តេជោមានឫទ្ធិ | | ១ |
| ៦៣ | អនុវិ.តាបែន | | ១ |
| ៦៤ | អនុវិ.កកោះ | | |
| ៦៥ | អនុវិ.ហស.ទ្រាស | | |
| ៦៦ | អនុវិ.តាផូ | | ១ |
| ៦៧ | អនុវិ.ថ្មគោល | | ១ |
| ៦៨ | អនុវិ.ប្រាសាទភាស | | |
| ៦៩ | វិ.ម៉ាឡៃ | ស្រុក ម៉ាឡៃ | ១ |
| ៧០ | វិ.អូរសំព័រ | | ១ |
| ៧១ | វិ.តាគង់ | | |
| ៧២ | អនុ.បឹងបេង | | ១ |
| ៧៣ | អនុវិ.អូរស្រឡៅ | | ១ |
| ៧៤ | អនុវិ.ទួលពង្រ | | ១ |
| ៧៥ | អនុវិ.ខ្នាយ | | |
| ៧៦ | វិ.អូរជ្រៅ | ក្រុង ប៉ោយប៉ែត | ១ |
| ៧៧ | វិ.ប៉ោយប៉ែតក្រុង | | ១ |
| ៧៨ | វិ.ទួលប្រាសាទ | | ១ |
| ៧៩ | វិ.និមិត្ត | | ១ |
| ៨០ | អនុវិ.គីឡូម៉ែត្រលេខ៤ | | |

| | | | |
|---|---|---|---|
| ៨១ | អនុវិ.បាលិលេយ្យ | | ១ |
| ៨២ | អនុវិ.អូរឫស្សី | | |
| ៨៣ | អនុវិ.គូបធំ | | ១ |
| ៨៤ | អនុវិ.ហាស.ស្រះត្រាច | | |
| សរុប | | | ៦២ |

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យបែបបរិមាណវិស័យត្រូវធ្វើឡើងដោយយកលទ្ធផលនៃចម្លើយរៀបទៅតាមតារាងដែលស្រង់ចេញពីកម្មវិធី Microsoft Excel ហើយធ្វើការវិភាគទៅលើតារាងនីមួយៗ ដោយរកតម្លៃមធ្យម ( Mean) រួចពិនិត្យមើលគម្លាតស្តង់ដា (SD)ដើម្បីពិនិត្យមើលថាតើតម្លៃមធ្យមដែលរកឃើញនោះ មានកម្រិតខុសគ្នាអាចទទួលយកបានឬទេ និងកំណត់កម្រិត (Level) នៃការអនុវត្តសកម្មភាព។ ម្យ៉ាងទៀត ការវិភាគទិន្នន័យបែបគុណវិស័យ អ្នកស្រាវជ្រាវវិភាគលើចម្លើយ ដែលបានមកពីសំណួរទម្រង់បើក របស់នាយក/នាយិកា ដោយធ្វើការស្រង់ពាក្យពេចន៍ក្នុងចម្លើយ ដែលដូចគ្នា ឬ ប្រហាក់ប្រហែលគ្នាដើម្បីទាញព័ត៌មានបន្ថែមអំពី បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន និងអនុសាសន៍ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះរបស់នាយក/នាយិការួចទាញសេចក្តីសន្និដ្ឋាន។

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

បន្ទាប់ពីប្រមូលទិន្នន័យបានហើយ អ្នកស្រាវជ្រាវបានស្រង់ និងរៀបចំវិភាគតាមផ្នែកទាំង៥របស់កម្រងសំណួរដូចខាងក្រោម៖

## ៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ

### ៤.១.១ ពត៌មានទូទៅរបស់អ្នកចូលរួមឆ្លើយ

*តារាងទី ១៖ ចំនួននាយកសាលាគិតតាមភេទ អាយុ និងរយៈពេលនៃបទពិសោធន៍*

| លរ. | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| ១ | ភេទ | ប្រុស | ៥២ | ៨៤% |
| | | ស្រី | ១០ | ១៦% |
| | | សរុប | **៦២** | ១០០% |
| ២ | រយៈពេលបំពេញការងារជានាយក/នាយិកា | ១ឆ្នាំ -៥ឆ្នាំ | ១០ | ១៦% |
| | | ៦ឆ្នាំ -១០ឆ្នាំ | ២០ | ៣២% |
| | | ១១ឆ្នាំ -១៥ឆ្នាំ | ១៩ | ៣១% |
| | | ១៦ឆ្នាំ -២០ឆ្នាំ | ១៣ | ២១% |
| | | សរុប | **៦២** | ១០០% |

តារាងទី៩ បង្ហាញថាលោកនាយកបានបំពេញកម្រងសណួរដោយផ្ទាល់ និងតាមGoogle Form មានចំនួន៦២នាក់ដែលក្នុងនោះមាននាយក៥២នាក់ និងនាយិកា១០នាក់។ រីឯចំនួនចន្លោះឆ្នាំរយៈពេលបំពេញការងាររបស់នាយក នាយិកា គឺ ពី១ដល់៥ឆ្នាំមាន ចំនួន១០នាក់ ស្មើនឹង១៦% ៦ដល់១០ឆ្នាំមាន

ចំនួន២០នាក់ ស្មើនឹង៣២% ១១ដល់១៥ឆ្នាំមានចំនួន១៩នាក់ស្មើនឹង៣១% ១៦ដល់២០ឆ្នាំមានចំនួន ១៣នាក់ស្មើនឹង២១%។

*តារាងទី 10៖ ចំនួនម៉ោងបន្ថែម និងចំនួនវេនបង្រៀន និងរៀន*

| | | | | |
|---|---|---|---|---|
| ១ | បង្រៀនម៉ោងបន្ថែម | មាន | ១០ | ១៦% |
| | | គ្មាន | ៥២ | ៨៤% |
| | | សរុប | **៦២** | ១០០% |
| ២ | ចំនួនវេនបង្រៀន | ១វេន | ៥០ | ៨១% |
| | | ២វេន | ១២ | ១៩% |
| | | សរុប | **៦២** | ១០០% |

តារាងទី១០បញ្ជាក់ថាក្នុងចំណោមសាលារៀនទាំង៦២ សាលាដែលមានបង្រៀនម៉ោងបន្ថែមមានចំនួនតែ១០សាលា និងសាលាដែលគ្មានម៉ោងបន្ថែមមាន៥២សាលា។ ចំណែកចំនួនវេនបង្រៀនវិញ សាលាចំនួន៥០សាលាបង្រៀន១វេន រីឯ១២សាលាទៀតបង្រៀនតែ១វេនទេ។

### ៤.១.២ ទីតាំងសាលារៀន

*តារាងទី 11៖ ទីតាំងសាលារៀនរបស់នាយកសាលាដែលបំពេញកម្រងសំណួរ*

| **ល.រ.** | **បរិយាយ** | | **ចំនួន** | **ភាគរយ** |
|---|---|---|---|---|
| ១ | ទីតាំងសាលា | ជនបទ | ៥៤ | ៨៧.១០% |
| | | ទីប្រជុំជន | ៨ | ១២.៩០% |
| | | សរុប | **៦២** | ១០០.០០% |

តារាងទី១១បង្ហាញថាសាលាដែលស្ថិតនៅទីប្រជុំជនមាន៨សាលាស្មើនឹង១២.៩០% និងនៅជនបទមាន៥៤សាលាស្មើនឹង៨៧.១០%។

### ៤.១.៣ ការកំណត់ពីតម្រូវការគ្រូកម្រិតមូលដ្ឋានទូទាំងខេត្តបន្ទាយមានជ័យ

អ្នកស្រាវជ្រាវពឹងផ្អែកឯកសារយោងបីជាស្តង់ដារធៀប ដើម្បីឱ្យការវិភាគទៅលើទិន្នន័យទាំងនេះមានភាពច្បាស់លាស់គឺ (១) សេចក្តីណែនាំស្តីពី និយាមប្រើប្រាស់បុគ្គលិកអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)(២)ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស (ក្រសួងអប់រំ យុវជន និងកីឡា ២០១៥)និង (៣)កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ២០១៨។

អថេរសំខាន់ៗដែលនឹងត្រូវវិភាគទិន្នន័យទូទាំងខេត្ត និងតាមស្រុក ក្រុងនីមួយៗ មានដូចជា ចំនួនសិស្ស ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូដែលត្រូវបែងចែកជាបីប្រភេទគឺ គ្រូតាមនិយាម(គ្រូដែលគិតតាមនិយាមប្រើប្រាស់បុគ្គលិកអប់រំលេខ២០)គ្រូកំពុងបង្រៀនជាក់ស្តែង (គ្រូដែលទទួលបានពីការស្រាវ-ជ្រាវតាមកម្រងសំណួរ) និងតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែង(គ្រូដែលគិតតាមនិយាម តែយកតាមចំនួនថ្នាក់ដែលទទួលបានជាក់ស្តែង)។

*តារាងទី 12៖ ស្ថិតិសិស្ស ថ្នាក់ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងទូទាំងខេត្ត*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **២១១២៤នាក់** | |
| ថ្នាក់ | ៥២៨ ថ្នាក់ | **៤៥០ ថ្នាក់** |
| ម៉ោង | ២១១២៤ ម៉ោង | ១៨០០០ ម៉ោង |
| គ្រូ | ១១៧៤ នាក់ | ១០០០ នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **៩៧៦ នាក់** | |

តារាងទី១២ បានមកពីការជ្រើសរើសសំណាកពីវិទ្យាល័យ និងអនុវិទ្យាល័យ ចំនួន៦២សាលាក្នុងចំណោម៩ស្រុកក្រុងទូទាំងខេត្តបន្ទាយមានជ័យ។ អ្នកស្រាវជ្រាវផ្តោតលើ អថេរសំខាន់ៗ ដូចជា ចំនួនសិស្ស ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូត្រូវបែងចែកជាបីប្រភេទ គឺគ្រូតាមនិយាម(១១៧៤នាក់) គ្រូកំពុងបង្រៀនជាក់ស្តែង(៩៧៦នាក់) តម្រូវការគ្រូតាមថ្នាក់ជាក់ស្តែង(១០០០នាក់)។ តារាងនេះបង្ហាញ

ថា ស្ថិតិក្នុងសំណាកដែលបានជ្រើសរើសមានសិស្សចំនួន២១១២៤នាក់ មាន៤៥០ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង៩៧៦នាក់នៅឆ្នាំសិក្សា ២០១៩-២០២០។

បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន៥២៨ថ្នាក់(២១១២៤ ចែកនឹង ៤០) និងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ២១១២៤ម៉ោង(៥២៨គុណ៤០) ត្រូវការគ្រូចំនួន ១១៧៤នាក់(២១១២៤ចែក១៨ បើតាមនិយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍។ ថ្នាក់ជាក់ស្តែង ដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៧៨ថ្នាក់(៥២៨ដកនឹង៤៥០)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់ទូទាំងខេត្តមិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។

មួយវិញទៀតកាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួន តម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាង ចំនួនគ្រូតាមនិយាមផងដែរនូវចំនួន១៧៤នាក់(១១៧៤ដកនឹង១០០០)។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន១៧៤នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ ក៏តិចជាងគ្រូតាមនិយាមចំនួន១៩៨នាក់ (១១៧៤ ដកនឹង៩៧៦)ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ខេត្តនេះខ្វះគ្រូកាន់តែច្រើនឡើង។

យ៉ាងណាមិញ ដើម្បីឱ្យការបង្រៀន និងរៀន ដំណើរការទៅបាន ការកំណត់និយាមសិស្សថ្នាក់តាមជាក់ស្តែងរបស់ខេត្តនេះគឺ មានចំនួន៤៦នាក់ក្នុងមួយថ្នាក់(២១១២៤ចែកនឹង៤៥០)ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថាខេត្តនេះ ខ្វះខាតបន្ទប់រៀនដែរ។ បើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៩ម៉ោងក្នុងមួយសប្តាហ៍ (៤៥០គុណនឹង៤០ចែកនឹង៩៧៦) ច្រើនជាងនិយាម ដែលកំណត់ដោយក្រសួង១៨ម៉ោង ក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់មានការខ្វះគ្រូផងដែរ។

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការខ្វះគ្រូ ដែលមានក្របខ័ណ្ឌកម្រិតមូលដ្ឋានដូចនេះក៏ដោយក៏មិនបញ្ជាក់ថា ខ្វះគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួន

គ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី១ខាងក្រោម។

*ក្រាបទី 1៖* ចំនួនគ្រូមានស្រាប់និងតម្រូវការគ្រូតាមនិយាមថ្មីតាមឯកទេសនីមួយៗទូទាំងខេត្ត




ក្រាបទី១នេះបង្ហាញឱ្យឃើញថាពីការប្រៀបធៀបរវាងគ្រូបង្រៀនកម្រិតមូលដ្ឋានមានស្រាប់និងគ្រូបង្រៀនកម្រោតមូលដ្ឋានតាមនិយាមការប្រើប្រាស់បុគ្គលិកអប់រំ។ ចំនួនគ្រូមុខវិជ្ជា ភាសាខ្មែរ ដែលត្រូវការសម្រាប់អនុវិទ្យាល័យ/វិទ្យាល័យសំណាក នៃស្រុក/ក្រុងទាំង៩នេះគិតតាមនិយាមត្រូវមាន២០៥នាក់ ប៉ុន្តែចំនួនគ្រូភាសាខ្មែរមានស្រាប់ដែលកំពុងបម្រើការក្នុងស្រុក/ក្រុងទាំងនេះមានរហូតដល់២៤៤នាក់។ នេះបញ្ជាក់ឱ្យឃើថាគ្រូភាសាខ្មែរលើសតម្រូវការ។ រីឯគ្រូមុខវិជ្ជា រូបវិទ្យា គីមីវិទ្យា ជីវៈវិទ្យា ផែនដីនិងប្រវត្តិវិទ្យាក៏លើលតម្រូវការផងដែរ។ តែដោយឡែកចំពោះមុខវិជ្ជា ភាសាបរទេស គណិតវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋ កុំព្យូទ័រ អប់រំកាយកីឡា អប់រំសិល្បៈ អប់រំសុខភាព និង បំណិនជីវិតតាមមូលដ្ឋាន នៅខ្វះតម្រូវការគ្រូ។ នេះសរបញ្ជាក់ថា ការផ្គត់ផ្គង់ និងការបែងចែកគ្រូបង្រៀនទៅតាមអនុវិទ្យាល័យ/វិទ្យាល័យគោលដៅនៃស្រុក/ក្រុងទាំង៩ ដែលលើកយកមកសិក្សានេះ នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

ការស្រាវជ្រាវនេះ ក៏បានពិនិត្យស៊ីជម្រៅផងដែរទៅលើអថេរស្រុកក្រុងនីមួយៗ ហើយលទ្ធផលដូចមានបង្ហាញខាងក្រោមៈ

### ៤.១.៣.១-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកមង្គលបូរី

*តារាងទី 13៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្ដែងក្នុងស្រុកមង្គលបូរី*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **៦៥០៤ នាក់** | |
| ថ្នាក់ | ១៦៣ថ្នាក់ | **១៣០ ថ្នាក់** |
| ម៉ោង | ៦៥០៤ម៉ោង | ៥២០០ម៉ោង |
| គ្រូ | ៣៦១នាក់ | ២៨៩នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **៣៥១ នាក់** | |

តារាងទី១៣បង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន៦៥០៤នាក់ មាន១៣០ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង៣៥១នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន១៦៣ថ្នាក់(៦៥០៤ចែកនឹង៤០) និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយ សប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៦៥០៤ម៉ោង(១៦៣គុណ៤០) ត្រូវការគ្រូចំនួន៣៦១នាក់(៦៥០៤ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់ តិចជាងថ្នាក់តាមនិយាមចំនួន៣៣ថ្នាក់(១៦៣ដកនឹង១៣០)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី១នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន៦២នាក់(៣៦១ដកនឹង ២៨៩)។សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន៦២នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀន

ជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន១០នាក់(៣៦១ដកនឹង៣៥១)ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ខ្វះគ្រូចំនួន១០នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន៥០នាក់ក្នុងមួយថ្នាក់(៦៥០៤ចែកនឹង១៣០) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់ ។នេះបញ្ជាក់ថា ស្រុកនេះ ក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៥ម៉ោងក្នុងមួយសប្តាហ៍(១៣០គុណនឹង៤០ចែកនឹង៣៥១) តិចជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់ មានការលើសគ្រូផងដែរ។

### ៤.១.៣.២-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកភ្នំស្រុក

*តារាងទី 14៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកភ្នំស្រុក*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **២៣១២ នាក់** | |
| ថ្នាក់ | ៥៨ថ្នាក់ | **៥៤ ថ្នាក់** |
| ម៉ោង | ២៣១២ម៉ោង | ២១៦០ម៉ោង |
| គ្រូ | ១២៨នាក់ | ១២០នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **១៤២ នាក់** | |

តារាងទី១៤ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន២៣១២នាក់ មាន៥៤ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង១៤២នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំត្រូវមាន៥៨ថ្នាក់(២៣១២ចែកនឹង៤០) និងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ២៣១២ម៉ោង (៥៨គុណ៤០) ត្រូវការគ្រូចំនួន១២៨នាក់(២៣១២ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៤ថ្នាក់(៥៨ដកនឹង៥៤)។ នេះបញ្ជាក់ឱ្យឃើញ

ថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី២នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្ដីណែនាំ ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ មានការខ្វះខាតតិចតួច។

មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្ដែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្ដែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន៨នាក់(១២៨ដកនឹង១២០)។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន៨នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្ដែងដែលមានស្រាប់ក៏ច្រើនជាងគ្រូតាមនិយាមចំនួន១៤នាក់ដែរ(១៤២ដកនឹង១២៨)។ នេះបញ្ជាក់ឱ្យឃើញថា លើសគ្រូចំនួន១៤នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្ដែងរបស់ស្រុកនេះ មានចំនួន៤២នាក់ក្នុងមួយថ្នាក់ (២៣១២ចែកនឹង៥៤) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថាស្រុកទី២ក៏ខ្វះខាតបន្ទប់រៀនតិចតួចដែរ។តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៥ម៉ោងក្នុងមួយសប្ដាហ៍(៥៤គុណនឹង៤០ចែកនឹង១៤២) តិចជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្ដាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្ដែងដែលមានស្រាប់ មានការលើសគ្រូផងដែរ។

### ៤.១.៣.៣-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកព្រះនេត្រព្រះ

*តារាងទី 15៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្ដែងក្នុងស្រុកព្រះនេត្រព្រះ*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្ដែង** |
|---|---|---|
| សិស្ស | **៣០៨៨ នាក់** | |
| ថ្នាក់ | ៧៧ថ្នាក់ | **៦១ ថ្នាក់** |
| ម៉ោង | ៣០៨៨ម៉ោង | ២៤៤០ម៉ោង |
| គ្រូ | ១៧២នាក់ | ១៣៦នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **១០១ នាក់** | |

តារាងទី១៥ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន៣០៨៨នាក់ មាន៦១ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង១០១នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន៧៧ថ្នាក់(៣០៨៨ ចែកនឹង៤០) និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៣០៨៨ម៉ោង (៧៧គុណ៤០) ត្រូវការគ្រូចំនួន១៧២នាក់(៣០៨៨ ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន១៦ថ្នាក់ (៧៧ដកនឹង៦១)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកនេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ដែលកំណត់ដោយសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន៣៦នាក់(១៧២ដកនឹង១៣៦)។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន៣៦នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៧១នាក់(១៧២ដកនឹង១០១)ដែរ។នេះបញ្ជាក់ឱ្យឃើញថា ខ្វះគ្រូចំនួន៧១នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកទី៣នេះមានចំនួន៥១នាក់ក្នុងមួយថ្នាក់(៣០៨៨ចែកនឹង៦១) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកនេះ ក៏ខ្វះខាតបន្ទប់រៀនតិចតួចដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ២៤ម៉ោងក្នុងមួយសប្តាហ៍(៦១គុណនឹង៤០ចែកនឹង១០១) ច្រើនជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោង ក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បីអនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់មានការខ្វះគ្រូផងដែរ។

### ៤.១.៣.៤-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកអូរជ្រៅ

*តារាងទី 16៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកអូរជ្រៅ*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **១២៣៩ នាក់** | |
| ថ្នាក់ | ៣១ថ្នាក់ | **២៦ ថ្នាក់** |
| ម៉ោង | ១២៣៩ម៉ោង | ១០៤០ម៉ោង |
| គ្រូ | ៦៩នាក់ | ៥៨នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **២៨ នាក់** | |

តារាងទី១៦ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន១២៣៩នាក់ មាន២៦ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង២៨នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំត្រូវមាន៣១ថ្នាក់(១២៣៩ចែកនឹង៤០) និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ១២៣៩ម៉ោង (៣១គុណ៤០) ត្រូវការគ្រូចំនួន៦៩នាក់(១២៣៩ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៥ថ្នាក់(៣១ដកនឹង២៦)។ នេះបញ្ជាក់ឱ្យឃើញថាការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី៤នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន១១នាក់ (៦៩ដកនឹង៥៨)។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន១១នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៤១នាក់ (៦៩ដកនឹង២៨)ដែរ។ នេះបញ្ជាក់ឱ្យឃើញថាខ្វះគ្រូចំនួន៤១នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន៤៨នាក់ក្នុងមួយថ្នាក់ (១២៣៩ចែកនឹង២៦) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និង

កីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ៣៧ម៉ោងក្នុងមួយសប្តាហ៍(២៦គុណនឹង៤០ចែកនឹង២៨) ច្រើនជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់ មានការខ្វះគ្រូច្រើនផងដែរ។

### ៤.១.៣.៥-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងសិរីសោភ័ណ

*តារាងទី 17៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងក្រុងសិរីសោភ័ណ*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **៤១៣៣ នាក់** | |
| ថ្នាក់ | ១០៣ថ្នាក់ | **៩៥ ថ្នាក់** |
| ម៉ោង | ៤១៣៣ម៉ោង | ៣៨០០ម៉ោង |
| គ្រូ | ២៣០នាក់ | ២១១នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **២២៤ នាក់** | |

តារាងទី១៧ នេះបង្ហាញថា ស្ថិតិក្នុងក្រុងនេះមានសិស្សចំនួន៤១៣៣នាក់ មាន៩៥ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង២២៤នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំត្រូវមាន១០៣ថ្នាក់(៤១៣៣ចែកនឹង៤០)និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៤១៣៣ម៉ោង (១០៣គុណ៤០) ត្រូវការគ្រូចំនួន២៣០នាក់(៤១៣៣ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៨ថ្នាក់(១០៣ដកនឹង៩៥)។នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី៥នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

ម៉្យាងវិញទៀតកាលណាចំនួនថ្នាក់ជាក់ស្ដែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្ដែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន១៩នាក់(២៣០ដកនឹង២១១)។ នេះបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន១៩នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្ដែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៦នាក់(២៣០ដកនឹង២២៤)ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ខ្វះគ្រូចំនួន៦នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្ដែងរបស់ក្រុងនេះ មានចំនួន៤៤នាក់ក្នុងមួយថ្នាក់ (៤១៣៣ចែកនឹង៩៥) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤០នាក់ក្នុងមួយថ្នាក់ ។នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ ។តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៧ម៉ោងក្នុងមួយសប្ដាហ៍(៩៥គុណនឹង៤០ចែកនឹង២២៤)តិចជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្ដាហ៍។បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្ដែងដែលមានស្រាប់ មានការលើសតិចតួចផងដែរ។

### ៤.១.៣.៦-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកថ្មពួក

*តារាងទី 18៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្ដែងក្នុងស្រុកថ្មពួក*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្ដែង** |
|---|---|---|
| សិស្ស | **២២១៧ នាក់** | |
| ថ្នាក់ | ៥៥ថ្នាក់ | **៤៦ ថ្នាក់** |
| ម៉ោង | ២២១៧ម៉ោង | ១៨៤០ម៉ោង |
| គ្រូ | ១២៣នាក់ | ១០២នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | ៨០ នាក់ | |

តារាងទី១៨ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន២២១៧នាក់មាន៤៦ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្ដែង៨០នាក់។ បើតាមសេចក្ដីណែនាំ ស្ដីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន៥៥ថ្នាក់និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្ដាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ

២២១៧ម៉ោង ត្រូវការគ្រូចំនួន១២៣នាក់។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន ៩ថ្នាក់។ នេះបញ្ជាក់ឱ្យឃើញថាការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី៦នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងចំនួនគ្រូតាមនិយាមផងដែរនូវចំនួន២១នាក់( ១២៣ដកនឹង១០២ )។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូ ចំនួន២១នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៤៣នាក់ (១២៣ដកនឹង៨០)ដែរ។ នេះបញ្ជាក់ឱ្យឃើញថា ខ្វះគ្រូចំនួន៤៣នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះ មានចំនួន៤៨នាក់ក្នុងមួយថ្នាក់(២២១៧ចែកនឹង៤៦) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និង កីឡា ៤០នាក់ក្នុងមួយថ្នាក់ ។នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ ។តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ២៣ម៉ោងក្នុងមួយសប្តាហ៍( ៤៦គុណនឹង៤០ចែកនឹង៨០ )ច្រើនជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បី អនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់ មានការខ្វះច្រើនផងដែរ។

### ៤.១.៣.៧-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកម៉ាឡៃ

*តារាងទី 19៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកម៉ាឡៃ*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **១៦៣១ នាក់** | |
| ថ្នាក់ | ៤១ថ្នាក់ | **៣៨ ថ្នាក់** |
| ម៉ោង | ១៦៣១ម៉ោង | ១៥២០ម៉ោង |
| គ្រូ | ៩១នាក់ | ៨៤នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **៥០ នាក់** | |

តារាងទី១៩ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន១៦៣១នាក់ មាន៣៨ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង៥០នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន៤១ថ្នាក់និង តាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងមួយថ្នាក់ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ១៦៣១ម៉ោង ត្រូវការគ្រូចំនួន៩១នាក់។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាងថ្នាក់តាមនិយាមចំនួន៣ថ្នាក់។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី៧នេះមិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។

កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងចំនួនគ្រូតាមនិយាមផងដែរនូវចំនួន៧នាក់(៩១ដកនឹង៨៤)។ សរបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន៧នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៤១នាក់ (៩១ដកនឹង៥០) ដែរ។ នេះបញ្ជាក់ឱ្យឃើញថាខ្វះគ្រូចំនួន៤១នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះមានចំនួន៤៣នាក់ក្នុងមួយថ្នាក់ (១៦៣១ចែកនឹង៣៨) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ៣០ម៉ោងក្នុងមួយសប្តាហ៍(៣៨គុណនឹង៤០ចែកនឹង៥០)ច្រើនជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បីអនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់មានការខ្វះច្រើនផងដែរ។

### ៤.១.៣.៨-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងស្រុកស្វាយចេក

*តារាងទី 20៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងស្រុកស្វាយចេក*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **២៤៥០ នាក់** | |
| ថ្នាក់ | ៦១ថ្នាក់ | **៥៣ ថ្នាក់** |
| ម៉ោង | ២៤៥០ម៉ោង | ២១២០ម៉ោង |
| គ្រូ | ១៣៦នាក់ | ១១៨នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **៩៨ នាក់** | |

តារាងទី២០ នេះបង្ហាញថា ស្ថិតិក្នុងស្រុកនេះ មានសិស្សចំនួន២៤៥០នាក់ មាន៥៣ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង៩៨នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំត្រូវមាន៦១ថ្នាក់(២៤៥០ចែកនឹង៤០) និងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ២៤៥០ម៉ោង(៦១គុណ៤០)ត្រូវការគ្រូចំនួន៦នា៣៦ក់(២៤៥០ចែក១៨)។ ថ្នាក់ជាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន៨ថ្នាក់ (៦១ដកនឹង៥៣)។នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុកទី៨នេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។

មួយវិញទៀត កាលណាចំនួនថ្នាក់ជាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ជាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន១៨នាក់(១៣៦ដកនឹង១១៨)។ នេះបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន១៨នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀន

ជាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន៣៨នាក់ (១៣៦ដកនឹង៩៨)ដែរ។ នេះបញ្ជាក់ឱ្យឃើញថាខ្វះគ្រូចំនួន៣៨នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ជាក់ស្តែងរបស់ស្រុកនេះមានចំនួន៤៦នាក់ក្នុងមួយថ្នាក់ (២៤៥០ចែកនឹង៥៣) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា ៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ២២ម៉ោងក្នុងមួយសប្តាហ៍(៥៣គុណនឹង៤០ចែកនឹង៩៨) ច្រើនជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បីអនុវត្តការបង្រៀនតាមថ្នាក់ជាក់ស្តែងដែលមានស្រាប់មានការខ្វះគ្រូច្រើនផងដែរ។

### ៤.១.៣.៩-ស្ថានភាពនៃការប្រើប្រាស់គ្រូក្នុងក្រុងប៉ោយប៉ែត

*តារាងទី 21៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាមថ្មី និងតាមជាក់ស្តែងក្នុងក្រុងប៉ោយប៉ែត*

| **ចំនួន** | **តាមនិយាម** | **តាមជាក់ស្តែង** |
|---|---|---|
| សិស្ស | **៣១៨១ នាក់** | |
| ថ្នាក់ | ៨០ថ្នាក់ | **៦៧ ថ្នាក់** |
| ម៉ោង | ៣១៨១ម៉ោង | ២៦៨០ម៉ោង |
| គ្រូ | ១៧៧នាក់ | ១៤៩នាក់ |
| **គ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀន** | **១៦៤ នាក់** | |

តារាងទី២១ នេះបង្ហាញថា ស្ថិតិក្នុងក្រុងនេះមានសិស្សចំនួន៣១៨១នាក់ មាន៦៧ថ្នាក់ និងគ្រូបង្រៀនកម្រិតមូលដ្ឋាន(ក្របខណ្ឌ ខ)កំពុងបង្រៀនជាក់ស្តែង១៦៤នាក់។ បើតាមសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ត្រូវមាន៨០ថ្នាក់(៣១៨១ចែកនឹង៤០) និងតាមក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិក្នុងមួយថ្នាក់ ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ៣១៨១ម៉ោង(៨០គុណ៤០) ត្រូវការគ្រូចំនួន១៧៧នាក់(៣១៨១ចែក១៨)។ ថ្នាក់

ដាក់ស្តែងដែលមានស្រាប់តិចជាង ថ្នាក់តាមនិយាមចំនួន១៣ថ្នាក់(៨០ដកនឹង៦៧)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ក្រុងនេះ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយសេចក្តីណែនាំ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅឡើយ។

មួយវិញទៀត កាលណាចំនួនថ្នាក់ដាក់ស្តែងតិចជាងចំនួនថ្នាក់តាមនិយាមនាំឱ្យចំនួនតម្រូវការគ្រូតាមថ្នាក់ដាក់ស្តែងក៏តិចជាងគ្រូតាមនិយាមផងដែរនូវចំនួន២៨នាក់(១៧៧ដកនឹង១៤៩)។ សបញ្ជាក់ឱ្យឃើញថាមានភាពខ្វះគ្រូចំនួន២៨នាក់ផងដែរ។ ម្យ៉ាងទៀតគ្រូបង្រៀនកម្រិតមូលដ្ឋានកំពុងបង្រៀនដាក់ស្តែងដែលមានស្រាប់ក៏តិចជាងគ្រូតាមនិយាមចំនួន១៣នាក់(១៧៧ដកនឹង១៦៤)ដែរ។នេះបញ្ជាក់ឱ្យឃើញថាខ្វះគ្រូចំនួន១៣នាក់បើគិតធៀបនឹងនិយាមប្រើប្រាស់បុគ្គលិកអប់រំថ្មី។

យ៉ាងណាមិញ ការរៀបចំនិយាមសិស្សថ្នាក់ដាក់ស្តែងរបស់ក្រុងនេះ មានចំនួន៤៧នាក់ក្នុងមួយថ្នាក់(៣១៨១ចែកនឹង៦៧) ដែលលើសនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួង អប់រំ យុវជន និងកីឡា៤០នាក់ក្នុងមួយថ្នាក់។ នេះបញ្ជាក់ថា ស្រុកនេះក៏ខ្វះខាតបន្ទប់រៀនដែរ។ តែបើវិភាគនិយាមម៉ោងគ្រូបង្រៀន គ្រូម្នាក់បង្រៀនតែ១៦ម៉ោងក្នុងមួយសប្តាហ៍(៦៧គុណនឹង៤០ចែកនឹង១៦៧)តិចជាងនិយាមដែលកំណត់ដោយក្រសួង១៨ម៉ោងក្នុងមួយសប្តាហ៍។ បង្ហាញឱ្យឃើញថាចំនួនគ្រូដើម្បីអនុវត្តការបង្រៀនតាមថ្នាក់ដាក់ស្តែងដែលមានស្រាប់ មានការលើសតិចតួចផងដែរ។

### ៤.១.៤ ទស្សនៈរបស់គណៈគ្រប់គ្រងលើការប្រើប្រាស់គ្រូបង្រៀន

តារាងទី២២ យើងសង្កេតឃើញថា អ្នកឆ្លើយសំណួរក្នុងកម្រិតនៃការអនុវត្តបានល្អ មានចំនួនច្រើនជាងគេគឺ៧១.៧៨% បន្ទាប់មកកម្រិតនៃការអនុវត្តបានល្អបង្គួរគឺ២៧.១៩% និងបានអនុវត្តបានកម្រិតមធ្យមគឺ១.០២% ។

*តារាងទី 22៖ ចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនៃការអនុវត្ត*

| ការប្រើប្រាស់គ្រូបង្រៀន | កម្រិត | | |
|---|---|---|---|
| | មធ្យម | ល្អបង្គួរ | ល្អ |
| ១. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | ៤ | ២៦ | ២៧ |
| ២. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 0 | ១៤ | ៤៣ |
| ៣. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ | 0 | ២១ | ៣៦ |
| ៤. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លាភាព និងប្រសិទ្ធភាព | 0 | ២៦ | ៣១ |
| ៥. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 1 | ២៤ | ៣២ |
| **ភាគរយនៃចំនួនអ្នកឆ្លើយសំណួរតាមកម្រិតនីមួយៗ** | **១.០២%** | **២៧.១៩%** | **៧១.៧៨%** |

តារាងទី២៣ ឆ្លុះបញ្ចាំងពីប្រសិទ្ធភាពក្នុងការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលានៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យពីតម្លៃមធ្យម(Mean)តម្លៃគម្លាតស្តង់ដា (SD) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពការប្រើប្រាស់បង្រៀន ។

*តារាងទី 23៖ កម្រិតនៃការអនុវត្តសកម្មភាពលម្អិតលើផ្នែកការប្រើប្រាស់គ្រូបង្រៀន*

| ការប្រើប្រាស់គ្រូបង្រៀន | តម្លៃមធ្យម | គម្លាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | 2.40 | 0.62 | ល្អ |
| ២. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 2.75 | 0.43 | ល្អ |
| ៣. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាលសិក្សាបានត្រឹមត្រូវ | 2.63 | 0.49 | ល្អ |
| ៤. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លាភាព និងប្រសិទ្ធភាព | 2.54 | 0.50 | ល្អ |
| ៥. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 2.54 | 0.54 | ល្អ |
| **សរុប** | 2.58 | 0.52 | ល្អ |

ការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យគឺយល់ស្របក្នុងកម្រិត “ល្អ” (មធ្យមភាគពិន្ទុ=២.៥៨)។ សូចនាករ "គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច” ទទួលបានការយល់ស្របខ្ពស់ជាងក្នុងកម្រិត “ល្អ” (មធ្យមភាគពិន្ទុ=២.៧៥) និងសូចនាករ “លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន” ទទួលបានការយល់ស្របទាបជាងគេតែស្ថិតក្នុងកម្រិត “ល្អ” (មធ្យមភាគពិន្ទុ=២.៤០)។

តារាងទី២៤ ឆ្លុះបញ្ចាំងពីការប្រើប្រាស់គ្រូបង្រៀនរបស់ នាយកសាលាអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ ពីតម្លៃមធ្យម (Mean) និងកម្រិត (Level) នៃការអនុវត្តសកម្មភាពសរុបលើការប្រើប្រាស់គ្រូបង្រៀន។

*តារាងទី 24៖ កម្រិតនៃការអនុវត្តសកម្មភាពលើការប្រើប្រាស់គ្រូបង្រៀន*

| ល.រ | ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន | តម្លៃមធ្យម | កម្រិត |
|---|---|---|---|
| ១ | ការប្រើប្រាស់គ្រូបង្រៀន | 2.58 | ល្អ |

តារាងទី២៤បានបង្ហាញពីមធ្យមភាគសរុបនៃការប្រើប្រាស់គ្រូបង្រៀន នៅអនុវិទ្យាល័យ/វិទ្យាល័យក្នុងខេត្តបន្ទាយមានជ័យ គឺយល់ស្របក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=២.៦៩)។ ការប្រើប្រាស់គ្រូបង្រៀនទទួលបានការយល់ស្របទាបជាងគេតែស្ថិតក្នុងកម្រិតល្អ(មធ្យមភាគពិន្ទុ=២.៥៨)។

អ្នកស្រាវជ្រាវរកឃើញនូវចំណុចខ្លាំង និងចំណុចដែលត្រូវកែលម្អមួយចំនួនតាមរយៈតារាងខាងលើនេះ ។ ការគ្រប់គ្រងរដ្ឋបាលសាលារៀនជាភារកិច្ចសំខាន់មួយរបស់អ្នកដឹកនាំក្នុងការធ្វើឱ្យប្រសើរឡើងផ្នែកគុណភាពនិងប្រសិទ្ធភាពអប់រំ ដើម្បីធ្វើការវាស់ស្ទង់ និងដោះស្រាយបញ្ហាប្រឈមលើការរៀបចំអង្គភាពមួយដោយផ្អែកលើ លិខិតបទដ្ឋានគតិយុត្តនានា សំដៅធ្វើឱ្យមានការអភិវឌ្ឍលើគ្រប់ផ្នែក ដូចជាការរៀបចំបរិស្ថានសិក្សា ការគ្រប់គ្រងបុគ្គលិក ការប្រើប្រាស់បុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ និងការត្រួតពិនិត្យវាយតម្លៃ ការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យស្ថិតិបុគ្គលិក ថ្នាក់ សិស្ស ការរៀបចំផែនការសកម្មភាពនិងគ្រប់គ្រងថវិកា ដើម្បីបង្ហាញភស្តុតាងជាក់លាក់ក្នុងការអនុវត្តអ្វីដែលថ្មីរបស់នាយកសាលារៀន។ ក្នុងការគ្រប់គ្រងលើការប្រើប្រាស់បុគ្គលិក នាយកសាលាត្រូវស្វែងយល់ពីសុខទុក្ខរបស់គ្រូបង្រៀន ដោយសិក្សាពីប្រវត្តិ កន្លែងស្នាក់នៅ ឈ្មោះ លេខទូរសព្ទ ចំណង់ចំណូលចិត្ត ថ្ងៃខែឆ្នាំចូលនិវត្តន៍ មានគោលការណ៍ស្នើដំឡើងកាំប្រាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ ក្នុងការលើកទឹកចិត្តបុគ្គលិកនៅក្នុងសាលា ណែនាំដល់គ្រូបង្រៀនឱ្យចេះថែទាំសុខភាព អនាម័យ ស្រឡាញ់ភាពស្អាត ស្រឡាញ់ពេលវេលាគោរពតាមតួនាទី ភារកិច្ច ការស្លៀកពាក់សមរម្យ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព និងគណនេយ្យភាព ជំរុញឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដើម្បីពង្រីក និងអភិវឌ្ឍចំណេះដឹងលើមុខវិជ្ជាឯកទេស ចិត្ត-គរុកោសល្យ និងបច្ចេកវិទ្យាព័ត៌មាន លើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព លើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

ចំណែកការប្រើប្រាស់គ្រូបង្រៀនវិញ នាយកសាលាក៏អនុវត្តបានល្អបង្គួរ ដោយពួកគាត់បានរៀបចំគ្រូបង្រៀនចំឯកទេសឱ្យអស់លទ្ធភាពរួចទើបគាត់យកគ្រូដែលខុសឯកទេសទៅជួយបង្រៀន ដើម្បីឱ្យសាលារបស់គាត់អាចដំណើរការបង្រៀន និងរៀនបាន។ ចំណែកឯគ្រូបង្រៀននៅសាលាទាំងនោះភាគច្រើនគឺយកចិត្តទុកដាក់ក្នុងការបំពេញការងារ និងមានមនសិការវិជ្ជាជីវៈជាគ្រូបង្រៀន។

### ៤.១.៥ បញ្ហាប្រឈមនិងដំណោះស្រាយរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន

#### ក. បញ្ហាប្រឈមលើការប្រើប្រាស់គ្រូបង្រៀន

ចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀនក្នុងចំណោមនាយកទាំង៦២(៧៤%) បានលើកឡើងថា សាលារបស់គាត់ខ្វះគ្រូបង្រៀនធ្វើឱ្យពិបាក ក្នុងការរៀបចំសិស្សឱ្យរៀនត្រូវតាមនិយាមកំណត់របស់ក្រសួង មានគ្រូមិនគ្រប់ឯកទេស ឯកទេសខ្លះគ្រូច្រើនលើសពីតម្រូវការ ការផ្ដល់គ្រូមកឱ្យសាលាពីសំណាក់មន្ទីរអប់រំយុវជន និងកីឡាខេត្តមិនត្រូវតាមតម្រូវការ គ្រូមានកន្លែងរស់នៅឆ្ងាយពីសាលារៀន គ្រូតាមឯកទេសមានមិនគ្រប់ ពិបាកក្នុងការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ គ្រូម្នាក់បង្រៀនពីរមុខវិជ្ជាឬច្រើនជាងនេះ គ្រូខ្លះបំពេញការងារមិនបានពេញលេញតាមការចាត់តាំង គ្រូមួយចំនួនតូចមកបង្រៀនយឺតម៉ោង និងពុំមានកិច្ចតែងការបង្រៀនបានទៀងទាត់ប្រចាំសប្ដាហ៍ គ្រូមួយចំនួនខ្វះមនសិការ គិតប្រយោជន៍ផ្ទាល់ជាធំ គ្រូខ្លះទៀតយកចិត្តទុកដាក់តែម៉ោងបង្រៀនបន្ថែមក្រៅពីម៉ោងរដ្ឋ គ្រូមួយចំនួនធំមានមុខរបរមួយទៀតនៅផ្ទះ គ្រូខ្វះចំណេះដឹងផ្នែក ICT និងប្រព័ន្ធអេឡិចត្រូនិច។

ស្របពេលជាមួយគ្នាតាមឯកសាររបស់លោកបណ្ឌិត ស៊ន សេងហុក(២០១៩) ក៏បានលើកឡើងអំពីបញ្ហាប្រឈមពាក់ព័ន្ធនឹងការបំពេញភារៈកិច្ចរបស់គ្រូបង្រៀនប្រហាក់ប្រហែលគ្នាដូចជា គ្រូបង្រៀនមិនមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងថ្នាក់រៀន មិនបានដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ បង្រៀនសិស្សគ្មានកិច្ចតែងការ វិន័យធូររលុង គ្មានយុទ្ធសាស្ត្រក្នុងការទប់ស្កាត់សិស្សរៀនយឺត មិនមានការស្រាវជ្រាវបន្ថែម គ្មានគំនិតច្នៃប្រឌិត ផ្នត់គំនិតនៅបុរាណ បង្រៀនពីរពេល មិនសូវមានពេលទំនេរដើម្បីស្រាវជ្រាវគ្មានមនសិការវិជ្ជាជីវៈមិនយកចិត្តទុកដាក់ក្នុងការបង្រៀនសិស្ស។

លទ្ធផលខាងលើបង្ហាញថាបញ្ហាប្រឈម ដែលកើតមានឡើងក្នុងការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិគឺដោយសារក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ធ្វើការបែងចែក និងផ្តល់គ្រូបង្រៀនទៅតាមគ្រឹះស្ថានមធ្យមសិក្សាមិនបានគ្រប់គ្រាន់តាមឯកទេស និងមិនបានត្រូវតាមតម្រូវការ។ សាលាខ្លះដែលស្ថិតនៅទីប្រជុំជន គឺសម្បូរគ្រូបង្រៀនលើសពីតម្រូវការ ចំណែកឯសាលាដែលនៅជនបទតែងតែជួបនូវបញ្ហាកង្វះគ្រូបង្រៀន។ ចំណែក (Kayode 2011) ក៏បានរកឃើញដែរថាសាលានៅទីក្រុងមានចំនួនគ្រូបង្រៀនច្រើនជាងសាលានៅទីជនបទ ដោយសាលាមធ្យមសិក្សាមួយចំនួននៅជនបទ មានគ្រូបង្រៀនត្រឹមតែ៧នាក់ប៉ុណ្ណោះដោយរាប់ទាំងនាយកសាលាផងដែរ ដូចនេះចំនួននេះមិនគ្រប់គ្រានសម្រាប់បង្រៀនសិស្សនោះទេ។

## ខ. ដំណោះស្រាយចំពោះបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលកើតមានឡើងនៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅសាលារបស់ខ្លួន នាយកសាលាភាគច្រើនបានចាត់តាំងគ្រូមុខវិជ្ជាផ្សេងទៅបង្រៀនមុខវិជ្ជាដែលខ្វះគ្រូ ដោយយកគ្រូផ្នែកវិទ្យាសាស្ត្រឱ្យជួយបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយគ្រូផ្នែកសង្គមជួយបង្រៀនផ្នែកសង្គម យកមន្ត្រីការិយាល័យទៅជួយបង្រៀន ជ្រើសរើសគ្រូដែលមានបទពិសោធបង្រៀនច្រើនឆ្នាំ មានចំណេះដឹងទូលំទូលាយ និងធ្វើការបំប៉នជាប្រចាំតាមរយៈការប្រជុំក្រុមបច្ចេកទេស១ខែម្តង រៀបចំកាលវិភាគបង្រៀនជាក់ស្តែង គ្រូម្នាក់បង្រៀន២ឬ៣ឬ៤ មុខវិជ្ជា ជំរុញឱ្យគ្រូបង្រៀនខិតខំស្រាវជ្រាវ( ទាំងមុខវិជ្ជាឯកទេសនិងមិនមែនឯកទេស ) ឱ្យគ្រូបង្រៀនជាលក្ខណៈម៉ោងបន្ថែមទៅតាមឯកទេសដែលខ្វះគ្រូ ហៅគ្រូដែលបំពេញការងារមិនបានល្អមកជួបប្រជុំដោះស្រាយបញ្ហានៃការបំពេញការងារ ប្រជុំ ណែនាំ លើកទឹកចិត្តបុគ្គលិកឱ្យគោរពពេលវេលា ដោយយោងទៅលើ សេចក្តីណែនាំរបស់ក្រសួងអប់រំ លេខ ៥៦ អយក ចំពោះសាលាដែលខ្វះបន្ទប់គឺខ្ចីបន្ទប់ និងខ្ចីគ្រូពីក្រោមកជួយការបង្រៀន។ ចំពោះវិទ្យាល័យមួយចំនួនគឺយកគ្រូឧត្តមជួយបង្រៀនបឋមភូមិ និងយកគ្រូមូលដ្ឋានជួយបង្រៀនទុតិយភូមិ ។ ពេលខ្លះអនុវិទ្យាល័យអាចស្នើសុំគ្រូបង្រៀនពីបឋមសិក្សាមកជួយបង្រៀនម៉ោងបន្ថែម។

ម្យ៉ាងទៀត ដើម្បីដោះស្រាយបញ្ហាខាងលើនេះ នាយកអនុវិទ្យាល័យ/វិទ្យាល័យនីមួយៗក្នុងខេត្ត មានវិធីសាស្ត្រដូចជា៖ បង្កើននិងបន្ថយនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ ប្រើគ្រូបង្រៀនខុសកម្រិត ឬខុសឯកទេសមកជួយបង្រៀន និង រៀបចំបង្កើតរបបម៉ោងបន្ថែមសម្រាប់មុខវិជ្ជាលើគ្រូ។

ពាក់ព័ន្ធនឹងលើស ខ្វះគ្រូក្រសួងអប់រំ យុវជន និងកីឡាក៏បានចេញសេចក្តីណែនាំស្តីពីការគ្រប់គ្រងគ្រូបង្រៀនលេខ៥៣ អយក.សណន ដើម្បីផ្តល់សំណោះស្រាយការលើសខ្វះតាមខេត្តដូចជា បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង(ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។

រីឯសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានចេញសេចក្តីណែនាំដើម្បីដោះស្រាយស្ថានភាពលើស ខ្វះគ្រូបង្រៀនស្រដៀងគ្នាដែរ ដូចជា ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានីខេត្តនិងគណៈកម្មការជ្រើសរើសប៉ុស្តិ៍ គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យាទៅបម្រើការនៅសាលារៀនដែលបានជ្រើសរើសត្រូវទៅបម្រើការនៅទីនោះ បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នាបន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច គ្រូបង្រៀនចេញថ្មីដែលមិនគោរពតាមលិខិតបង្គាប់ការឬលិខិតឧទ្ទេសនាមនឹងត្រូវស្នើផ្អាកបៀវត្សឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

### ៤.១.៦ មតិយោបល់បន្ថែមរបស់នាយកសាលាលើការប្រើប្រាស់គ្រូបង្រៀន

ចំពោះការប្រើប្រាស់គ្រូបង្រៀន នាយក នាយិកា បានលើកឡើងថា ប្រើប្រាស់គ្រូអនុវត្តទៅតាមនិយាម ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាឱ្យអស់លទ្ធភាព ទើបយកគ្រូឯកទេសផ្សេងទៅជួយបង្រៀនដើម្បីដោះស្រាយឱ្យសាលាអាចដំណើរការទៅបានរលូន តែមុននិងយកគ្រូដែលខុសឯកទេសទៅជួយបង្រៀនគឺ ត្រូវពិនិត្យកម្រិតយល់ដឹងរបស់គាត់ ដើម្បីចាត់តាំងឱ្យទៅបង្រៀន មុខវិជ្ជាដែលខ្វះ។ ការប្រើប្រាស់គ្រូយោងទៅលើ កត្តាមួយចំនួនរួមមាន មនសិការ ជំនាញឯកទេសវិជ្ជាជីវៈ ក្រមសីលធម៌ រួមផ្សំចំណេះដឹងផ្នែកបច្ចេកវិទ្យាពត៌មាន និងភាសាបរទេស។

ជាការសង្ខេបឡើងវិញពាក់ព័ន្ធនឹងចំនួនលើសខ្វះគ្រូបង្រៀនកម្រិតមូលដ្ឋាន អ្នកស្រាវជ្រាវវិភាគដោយផ្អែកលើសេចក្តីណែនាំស្តីពីនិយាមប្រើបុគ្គលិកអប់រំ របស់ក្រសួងអប់រំគឺនិយាមថ្មីលេខ២០ អយក.សណន ដែលដាក់ឱ្យប្រើប្រាស់តាំងពីឆ្នាំសិក្សា២០១៨-២០១៩។ ដើម្បីឱ្យច្បាស់លាស់តាមឯកទេសសូមមើលតារាងសង្ខេបខាងក្រោមដែលរៀបរាប់ពី ចំនួនគ្រូលើខ្វះតាមមុខវិជ្ជាឯកទេសនីមួយៗ និងសរុបរួមតាមនិយាមថ្មី។

*តារាងទី 25៖ ចំនួនគ្រូលើសឬខ្វះតាមមុខវិជ្ជា និងសរុបរួមតាមនិយាមថ្មី*

| ល.រ | មុខវិជ្ជាបង្រៀន | ចំ.ម៉/ថ្នាក់ | គ្រូបង្រៀនកម្រិតមូលដ្ឋានដែលមានស្រាប់ | តម្រូវការគ្រូបង្រៀនកម្រិតមូលដ្ឋានតាមនិយាមថ្មី | លើស | ខ្វះ |
|---|---|---|---|---|---|---|
| ១ | ភាសាខ្មែរ | 7 | 244 | 205 | 39 | 0 |
| ២ | ភាសាបរទេស | 6 | 125 | 176 | 0 | 51 |
| ៣ | គណិតវិទ្យា | 7 | 156 | 205 | 0 | 49 |
| ៤ | រូបវិទ្យា | 2 | 79 | 59 | 20 | 0 |
| ៥ | គីមីវិទ្យា | 1 | 34 | 29 | 5 | 0 |
| ៦ | ជីវៈវិទ្យា | 2 | 73 | 59 | 14 | 0 |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | 1 | 34 | 29 | 5 | 0 |
| ៨ | ប្រវត្តិវិទ្យា | 2 | 62 | 59 | 3 | 0 |
| ៩ | ភូមិវិទ្យា | 2 | 48 | 59 | 0 | 11 |
| ១០ | សីលធម៌-ពលរដ្ឋវិជ្ជា | 2 | 52 | 59 | 0 | 7 |
| ១១ | គេហវិទ្យា | 1 | 32 | 29 | 3 | 0 |
| ១២ | កុំព្យូទ័រ(ICT) | 2 | 4 | 59 | 0 | 55 |
| ១៣ | អប់រំកាយនិងកីឡា | 2 | 27 | 59 | 0 | 32 |
| ១៤ | អប់រំសិល្បៈ | 1 | 2 | 29 | 0 | 27 |
| ១៥ | អប់រំសុខភាព | 1 | 0 | 29 | 0 | 29 |
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | 1 | 4 | 29 | 0 | 25 |
| **សរុបចំនួន** | | **40** | **976** | **1174** | **198** | |

តារាងទី២៥បង្ហាញពីចំនួនមុខវិជ្ជា ចំនួនម៉ោងក្នុងមួយថ្នាក់ ចំនួនគ្រូកម្រិតមូលដ្ឋានដែលមានស្រាប់ ចំនួនគ្រូតាមតម្រូវការនិយាមថ្មី និងចំនួនលើស ខ្វះគ្រូបង្រៀនតាមឯកទេសនីមួយៗ។ ក្នុងការបែងចែកថ្នាក់រៀនមួយថ្នាក់ត្រូវដាក់សិស្សចំនួន៤០នាក់ និងក្នុងមួយថ្នាក់ត្រូវរៀន៤០ម៉ោងក្នុងមួយសប្តាហ៍។ បើបែងចែកតាមនិយាមថ្មីនេះឃើញថាខ្វះគ្រូចំនួន១៩៨នាក់( ១១៧៤ដកនឹង៩៧៦ )។

# ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលធំៗបីគឺ ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅសាលាមធ្យមសិក្សាបឋមភូមិ បញ្ហាប្រឈមដែលបានកើតឡើងក្នុងការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលា និងដំណោះស្រាយរបស់នាយកសាលាលើបញ្ហាប្រឈមដែលបានកើតឡើង។

ឆ្លងតាមការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានរកឃើញថា ការប្រើប្រាស់គ្រូបង្រៀនមានលក្ខណៈល្អគួរឱ្យកត់សំគាល់ (ល្អស្មើនឹង៧១.៧៨%) ដោយនាយកសាលាបានធ្វើការប្រើប្រាស់គ្រូដោយរៀបចំគ្រូឱ្យទទួលភារកិច្ច តាមដានការបំពេញការងាររបស់គ្រូ ការធ្វើអធិការកិច្ចជាប្រចាំ។

ចំណែកបញ្ហាប្រឈមទៅលើការប្រើប្រាស់គ្រូវិញនោះគឺ សាលាមួយចំនួនដែលស្ថិតនៅតាមទីប្រជុំជនគឺមានចំនួនគ្រូលើសពីតម្រូវការ រីឯសាលានៅជនបទមានបញ្ហាកង្វះគ្រូនាំឱ្យនាយកសាលាជួបការលំបាកក្នុងការរៀបចំចំនួនថ្នាក់រៀន ការធ្វើបំណែងចែកភារកិច្ច និងកាលវិភាគ។ ការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យដែលនៅក្នុងវិទ្យាល័យ គណៈគ្រប់គ្រងក៏ជួបការលំបាកដូចជា ឥទ្ធិពលនៃការប្រើប្រាស់គ្រូបង្រៀនមិនទាន់មានប្រសិទ្ធភាពដោយសារមូលហេតុ នាយក នាយិកា (១)នាយក នាយិកាមានកម្រិតវប្បធម៌ទាបជាងបុគ្គលិក (២) នាយក នាយិកាខ្លះមានវ័យចំណាស់ និង (៣)គណៈគ្រប់គ្រងខ្វះចំណេះដឹងផ្នែកកុំព្យូទ័រ និងបច្ចេកវិទ្យា។

ចំពោះដំណោះស្រាយវិញ សាលាដែលលើសគ្រូ នាយកសាលាបានឱ្យគ្រូកម្រិតមូលដ្ឋានទាំងនោះទៅជួយបង្រៀននៅផ្នែកទុតិយភូមិ។ ចំពោះសាលាដែលខ្វះគ្រូ នាយកត្រូវរៀបចំម៉ោងបន្ថែមឱ្យបុគ្គលិកដោយគ្រូមួយចំនួនបង្រៀនតែ៦ទៅ៨ម៉ោង ឬច្រើនជាននេះ ក្នុងមួយសប្តាហ៍។ មួយវិញគណៈគ្រប់គ្រងត្រូវស្នើសុំបុគ្គលិកខ្លះឱ្យធ្វើជាបុគ្គលិកការិយាល័យ ដើម្បីជួយសម្រួលការងារ រដ្ឋបាល និងបច្ចេកទេស។

## ៥.២ សំណូមពរ

បើទោះបីជាលទ្ធផលដែលបានរកឃើញបង្ហាញថា ការប្រើប្រាស់គ្រូបង្រៀនរបស់នាយកសាលាកម្រិតមធ្យមសិក្សាបឋមភូមិនៅអនុវិទ្យាល័យ/វិទ្យាល័យនានាក្នុងខេត្តបន្ទាយមានជ័យ ស្ថិតក្នុងកម្រិតមួយល្អយ៉ាងណាក៏ដោយក៏អ្នកស្រាវជ្រាវ សូមលើកឡើងនូវសំណូមពរមួយ ចំនួនដើម្បីកែលម្អចំណុចខ្វះខាត

ដែលភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

**ក្រសួងអប់រំ យុវជន និងកីឡា៖**

- សូមបើកវគ្គបណ្តុះបណ្តាលបន្តដល់គណៈគ្រប់គ្រងសាលាផ្តោតទៅលើ ការគ្រប់គ្រង ដឹកនាំ និងប្រើប្រាស់គ្រូបង្រៀន ដើម្បីឱ្យការដឹកនាំអង្គភាពសាលារៀនប្រព្រឹត្តិទៅដោយភាពរលូន និងមានប្រសិទ្ធភាព
- សូមជ្រើសរើសគ្រូបង្រៀនទៅតាមមុខវិជ្ជាឯកទេសដែលកំពុងខ្វះឱ្យបានគ្រប់ចំនួន និងផ្តល់ទៅសាលាដែលកំពុងជួបនូវបញ្ហាខ្វះគ្រូបង្រៀន ។

**មន្ទីរអប់រំ យុវជននិងកីឡាខេត្ត៖**

- សូមបែងចែកគ្រូបង្រៀនតាមឯកទេស ដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន
- សូមពង្រឹងការអនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ស្នើដល់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ចុះអធិការកិច្ចសាលារៀនជាប្រចាំ និងកែលម្អ ព្រមទាំងផ្តល់អនុសាសន៍រាល់ចំណុចខ្វះខាតរបស់សាលា
- ស្នើសុំអនុញ្ញាតការផ្លាស់ចេញតែពីសាលាដែលលើសគ្រូ និងផ្ទេរចូលទៅសាលាដែលខ្វះគ្រូ។

**គណៈគ្រប់គ្រងសាលា៖**

- សូមរៀបចំគ្រូបង្រៀនឱ្យបានមានប្រសិទ្ធភាព ដោយការរៀបចំគ្រូត្រូវឯកទេសឱ្យអស់លទ្ធភាពទើបយកគ្រូដែលខុសឯកទេសមកជួយ តែត្រូវរៀបចំការប៉ប៉នគ្រូខុសឯកទេសបន្ថែមមុននឹងប្រើប្រាស់
- ពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងសុខដុមបនីយកម្មក្នុងអង្គភាព
- ពង្រឹងចំណេះដឹងផ្នែក ICT
- ពង្រឹងការងារអធិការកិច្ចឱ្យបានទៀងទាត់។

**គ្រូបង្រៀន៖**

- គោរពតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលា និងបំពេញការងារប្រកបដោយមនសិការវិជ្ជាជីវៈខ្ពស់ ដើម្បីឱ្យលទ្ធផលការងារប្រកបដោយប្រសិទ្ធភាព
- បង្រៀន និងរៀនដោយប្រើបេះដូងគិតគិតប្រយោជន៍រួមជាធំ ពោលគឺគិតពីអនាគតរបស់សិស្ស
- ពង្រឹងសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនឡើងវិញ។

**អ្នកស្រាវជ្រាវបន្ត៖**

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើការប្រើប្រាស់គ្រូបង្រៀនក្នុងកម្រិតមធ្យមសិក្សាបឋមភូមិក្នុងក្នុងខេត្តបន្ទាយមានជ័យហើយការប្រមូលទិន្នន័យគឺយកចេញពីទស្សនៈយល់ឃើញនាយកសាលាតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើ ចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការគ្រប់គ្រង និងការប្រើប្រាស់គ្រូបង្រៀននៅខេត្តបន្ទាយមានជ័យដដែល ឬនៅខេត្តដទៃទៀតឱ្យបានស៊ីជម្រៅ ទិន្នន័យគួរតែទទួលបានពី គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្សតែជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការធ្វើសម្ភាសន៍ផ្ទាល់
- ការសិក្សាស្រាវជ្រាវពីទស្សនៈយល់ឃើញរបស់គ្រូបង្រៀនទៅលើការគ្រប់គ្រងរបស់នាយកសាលាកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- សិក្សាអំពីស្ថានភាពការបំពេញតួនាទី ភារកិច្ចរបស់គ្រូបង្រៀនទាំងផ្នែកបឋមភូមិ និងទុតិយភូមិ
- គុណសម្បត្តិ និងគុណវិបត្តិរបស់គ្រូបង្រៀនក្រៅម៉ោងតាមកម្រិតសិក្សានីមួយៗ
- ឈ្វេងយល់ពីការគ្រប់គ្រងវិន័យសិស្ស និងគ្រូ
- សិក្សាស្ថានភាពបរិស្ថាន ការគ្រប់គ្រងសំរាមកាកសំណល់ និងអនាម័យសុខភាពតាមសាលារៀន។

# ឯកសារយោង


-គីម អឿន (២០១៦) ទូតសុច្ចន្ទៈភាពជាអ្នកដឹកនាំ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០០២)សេចក្តីណែនាំស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០០៦)កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ភ្នំពេញ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៥)ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស ភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៧)ស្តង់ដានាយសាលារៀន ភ្នំពេញ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៧)សេចក្តីណែនាំលេខ ២៣ អយក.សណន ស្តីពី ការបែង ចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៨)សេចក្តីណែនាំ លេខ ២០ អយក សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ភ្នំពេញ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០២៣ ភ្នំពេញ។

-ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)សេចក្តីណែនាំ លេខ៥៣ អយក.សណន ស្តីពីការគ្រប់គ្រងគ្រូបង្រៀន ។

-ណាត ជួន(១៩៦៧)វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួនណាត។

-នូវ វ៉ា(២០១៩)ការគ្រប់គ្រងប្រសិទ្ធភាពបុគ្គល។

-ពីង គិមឆេន(២០១៩)វឌ្ឍនភាពនៃការដឹកនាំគ្រប់គ្រងសាលារៀនសតវត្សទី២១។

-រាជរដ្ឋាភិបាល(២០១៨)អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

-ស៊ិន សេងហុក(២០១៩)ទស្សនវិជ្ជានៃការអប់រំ ច្បាប់អប់រំ និងគោលនយោបាយអប់រំ ។

–ហង់ជួន ណារ៉ុន(២០២០)កំណែទម្រង់សាលារៀននៅកម្ពុជា។

–Glenn D Israel (1992). Determining Sampe Size. University Florida.

–IIEP (2015) International Institute for Education Planning.

–J. D. Kayode (2011). Demand, Supply and Utilization of Secondary School Mediterranean Journal of Social Sciences, 69-77.

–J. W. Best (1981). Research in Education. Englewood Cliffs, 4th Edition ed., New York, Jersey: Prentice Hall, Inc.

–Longman Dictionary (2010) Longman Dictionary Oxford.

–Organisation for Economic Co-operation and Development OECD (2005). Annual Report.

–SEAMEO (2011) Success Competencies of Southeast Asian School Heads: A Learning Guide (Khmer Translation). Quezon: SEAMEO INNOTECH.

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំយុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន នៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តបន្ទាយមានជ័យ

ខ្ញុំបាទឈ្មោះ **ឌី សុផល** ជានិស្សិតរៀនវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី ៣ នៅវិទ្យាស្ថានជាតិអប់រំ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិក្នុងខេត្តបន្ទាយមានជ័យ**" ដើម្បីបំពេញលក្ខខណ្ឌក្នុងការសិក្សា។ គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនេះគឺស្វែងយល់ពីស្ថានភាពនៃការគ្រប់គ្រង និងដឹកនាំ នៅកម្រិតមធ្យមសិក្សាបឋមភូមិ លើការប្រើប្រាស់គ្រូបង្រៀន និងការគ្រប់គ្រងគ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិ។ ការសិក្សាក៏សំដៅស្វែងរកពីបញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិផងដែរ។ ទិន្នន័យដែលប្រមូលបានពីការសិក្សានេះ គឺប្រើសម្រាប់តែក្នុងការវិភាគ និងបកស្រាយទៅលើប្រធានបទស្រាវជ្រាវខាងលើតែប៉ុណ្ណោះ។ រាល់ពត៌មានរបស់លោក លោកស្រី នឹងត្រូវរក្សាទុកជាការសម្ងាត់។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយិកា មេត្តាជួយផ្តល់ទិន្នន័យ ក្នុងកម្រងសំណួរ ដោយឆ្លើយតបទៅតាមស្ថានភាព នៃការគ្រប់គ្រង និងដឹកនាំសាលារៀន លើការអនុវត្តកិច្ចការងារប្រចាំថ្ងៃ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោក លោកស្រីដែលបានចូលរួមឆ្លើយ និងបំពេញកម្រងសំណួរខាងក្រោមនេះ។

**ផ្នែក"ក" ៖ ព័ត៌មានទូទៅ**

១. ភេទ ☐ប្រុស ☐ស្រី

២. រយៈពេលបំពេញការងារជានាយក/នាយករង........................................................

☐១-៥ ឆ្នាំ ☐៦-១០ឆ្នាំ ☐១១-១៥ឆ្នាំ ☐១៦-២០ឆ្នាំ

៣. ឈ្មោះសាលា.....................................................

៤.បង្រៀនម៉ោងបន្ថែម ☐មាន ☐គ្មាន

៥.ចំនួនវេនបង្រៀន ៖ ☐មួយវេន ☐ពីរវេន

៦. សាលាមានទីតាំងស្ថិតក្នុងស្រុក........................................................

និងស្ថិតក្នុងតំបន់៖ ☐ទីប្រជុំជន ☐ជនបទ

**ផ្នែក ខ ៖ ការកំណត់ពីតម្រូវការ**

១.តើសាលារបស់លោក លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?

- ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៨៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
- ថ្នាក់ទី៩៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់

៣.តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)

- ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន (ក្របខណ្ឌ ខ) | ផ្សេងៗ |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |

| | | | |
|---|---|---|---|
| ៣ | គណិតវិទ្យា | | |
| ៤ | រូបវិទ្យា | | |
| ៥ | គីមីវិទ្យា | | |
| ៦ | ជីវៈវិទ្យា | | |
| ៧ | ផែនដី និងបរិស្ថានវិទ្យា | | |
| ៨ | ប្រវត្តិវិទ្យា | | |
| ៩ | ភូមិវិទ្យា | | |
| ១០ | សីលធម៌-ពលរដ្ឋវិជ្ជា | | |
| ១១ | គេហវិទ្យា | | |
| ១២ | កុំព្យូទ័រ(ICT) | | |
| ១៣ | អប់រំកាយនិងកីឡា | | |
| ១៤ | អប់រំសិល្បៈ | | |
| ១៥ | អប់រំសុខភាព | | |
| ១៦ | បំណិនជីវិតតាមមូលដ្ឋាន | | |
| **សរុបចំនួន** | | | |

ក្នុងផ្នែក "គ" ខាងក្រោម សូមលោក លោកស្រីបំពេញកម្រងព័ត៌មានដោយគូសរង្វង់ជុំវិញលេខទៅតាមកម្រិតដែលលោក លោកស្រីបានអនុវត្ត ។

** សម្គាល់៖ 1 = មធ្យម 2 = ល្អបង្គួរ 3 = ល្អ*

**ផ្នែក "គ" ៖ ទស្សនៈរបស់គណៈគ្រប់គ្រង លើការប្រើប្រាស់គ្រូបង្រៀន**

| | | | |
|---|---|---|---|
| ១. លោក លោកស្រីបានរៀបចំគ្រូបង្រៀនឱ្យបង្រៀនចំឯកទេសរបស់ខ្លួន | 1 | 2 | 3 |
| ២.គ្រូបង្រៀននៅសាលារបស់លោក លោកស្រីមកបំពេញការងារបានទៀងទាត់តាមបំណែងចែកភារកិច្ច | 1 | 2 | 3 |

| | | | |
|---|---|---|---|
| ៣. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីបានអនុវត្តរដ្ឋបាល | 1 | 2 | 3 |
| ៤. គ្រូបង្រៀននៅសាលារបស់លោក លោកស្រីវាយតម្លៃសិស្សប្រកបដោយតម្លាភាព និង មាប្រសិទ្ធភាព | 1 | 2 | 3 |
| ៥. លោក លោកស្រីធ្វើការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនដោយចុះអធិការកិច្ចតាមផែនការជាទៀងទាត់ | 1 | 2 | 3 |

**ផ្នែក "ឃ"៖ បញ្ហាប្រឈម និងដំណោះស្រាយ**

១. តើលោក/លោកស្រីជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅសាលារៀនរបស់លោក លោកស្រី?

............................................................................................................................

............................................................................................................................

............................................................................................................................

២. តើលោក/លោកស្រីមានវិធីសាស្ត្រអ្វីខ្លះដើម្បីដោះស្រាយបញ្ហាប្រឈមលើការប្រើប្រាស់គ្រូនៅសាលារៀនរបស់លោក លោកស្រី?

............................................................................................................................

............................................................................................................................

**ផ្នែក "ខ"៖ មតិយោបល់បន្ថែម**

សូមលោក លោកស្រីផ្តល់យោបល់បន្ថែមទៅលើដំណើរការខាងក្រោម៖

**ការប្រើប្រាស់គ្រូបង្រៀន**

......................................................................................................................................

......................................................................................................................................

*សូមអរគុណ*

*លេខទូរសព្ទនិងតេលេក្រាម ៖ 092 218031/ 093 535321*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ

លេខ : ១៣៤ វជអ. នក

# លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្ដីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្ដាល |
| 2 | ទុន វណ្ណៈ | ប | កណ្ដាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្ហា | ស | មណ្ឌលគីរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | វួច រី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | រីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត. ទេសឿង សុខឡា

**កន្លែងទទួល៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៦ វជអ.ឆក

ថ្ងៃ ៧រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២០

លេខ...៧៤១៩...
ថ្ងៃទី ៣ ខែ ០៨ ឆ្នាំ ២០២០
ម៉ោង............

**ជម្រាបជូន**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខណ្ណា

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តបន្ទាយមានជ័យ

# ស្ថិតិក្របខណ្ឌបុគ្គលិកអប់រំ
# បម្រើការនៅតាមអង្គភាពនានាក្នុងខេត្តបន្ទាយមានជ័យ
# ឆ្នាំសិក្សា ២០១៩-២០២០

រៀបចំដោយៈ ការិយាល័យ បុគ្គលិក បណ្តុះបណ្តាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តបន្ទាយមានជ័យ

## ស្ថិតិក្របខណ្ឌ បុគ្គលិកអប់រំ បម្រើការនៅតាម វិទ្យាល័យ នានា ឆ្នាំសិក្សា ២០១៩-២០២០

| ល.រ | ឈ្មោះអង្គភាព | ចំនួន | | | ស្ថានភាពក្របខ័ណ្ឌ | | | | | | | | | | | | | | សរុបក្របខណ្ឌ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | អធិការអប់រំ | | គ្រូឧត្តម | | គ្រូមូលដ្ឋាន | | អប់រំកាយ-កីឡា | | គ្រូបឋម | | គ្រូមត្តេយ្យ | | ភ្នាក់ងាររដ្ឋបាល | | | |
| | | អង្គភាព | ថ្នាក់រៀន | សិស្ស | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ស្រុក មង្គលបូរី | 5 | 129 | 6347 | 0 | 0 | 152 | 57 | 229 | 133 | 6 | 1 | 2 | 0 | 0 | 0 | 0 | 0 | 389 | 191 |
| 2 | ស្រុក ភ្នំស្រុក | 3 | 49 | 1904 | 0 | 0 | 36 | 9 | 98 | 40 | 2 | 0 | 4 | 1 | 0 | 0 | 1 | 0 | 141 | 50 |
| 3 | ស្រុក ព្រះនេត្រព្រះ | 5 | 79 | 3781 | 0 | 0 | 70 | 25 | 96 | 35 | 6 | 0 | 3 | 0 | 0 | 0 | 0 | 0 | 175 | 60 |
| 4 | ស្រុក អូរជ្រៅ | 2 | 21 | 1023 | 0 | 0 | 11 | 0 | 23 | 7 | 3 | 1 | 4 | 0 | 0 | 0 | 0 | 0 | 41 | 8 |
| 5 | ក្រុង សិរីសោភ័ណ | 4 | 139 | 6317 | 0 | 0 | 157 | 52 | 174 | 86 | 7 | 3 | 0 | 0 | 0 | 0 | 0 | 0 | 338 | 141 |
| 6 | ស្រុក ថ្មពួក | 2 | 39 | 1867 | 0 | 0 | 41 | 6 | 49 | 19 | 4 | 1 | 1 | 0 | 0 | 0 | 0 | 0 | 95 | 26 |
| 7 | ស្រុក ស្វាយចេក | 2 | 37 | 1859 | 0 | 0 | 25 | 4 | 34 | 13 | 2 | 1 | 4 | 1 | 0 | 0 | 0 | 0 | 65 | 19 |
| 8 | ស្រុក ម៉ាឡៃ | 3 | 35 | 1414 | 0 | 0 | 27 | 10 | 34 | 12 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 62 | 22 |
| 9 | ក្រុង ប៉ោយប៉ែត | 4 | 66 | 2977 | 0 | 0 | 79 | 17 | 86 | 32 | 7 | 0 | 2 | 1 | 0 | 0 | 0 | 0 | 174 | 50 |
| សរុបរួម | | 30 | 594 | 27489 | 0 | 0 | 598 | 180 | 823 | 377 | 38 | 7 | 20 | 3 | 0 | 0 | 1 | 0 | 1480 | 567 |

ថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
បន្ទាយមានជ័យ, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩
ជ-ប្រធានការិយាល័យបុគ្គលិក
អនុប្រធាន

សម សុស

បានឃើញ និងឯកភាព
ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
អនុប្រធាន

ទិម តាំងស៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តបន្ទាយមានជ័យ

## ស្ថិតិក្របខណ្ឌ បុគ្គលិកអប់រំ បម្រើការនៅតាម អនុវិទ្យាល័យ នានា ឆ្នាំសិក្សា ២០១៩-២០២០

| ល.រ | ឈ្មោះអង្គភាព | ចំនួន | | | ស្ថានភាពក្របខ័ណ្ឌ | | | | | | | | | | | | សរុបក្របខណ្ឌ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | គ្រូឧត្តម | | គ្រូមូលដ្ឋាន | | អប់រំកាយ-កីឡា | | គ្រូបឋម | | គ្រូមត្តេយ្យ | | ភ្នាក់ងាររដ្ឋបាល | | | |
| | | អង្គភាព | ថ្នាក់រៀន | សិស្ស | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 1 | ស្រុក មង្គលបូរី | 10 | 68 | 3380 | 0 | 0 | 5 | 1 | 181 | 97 | 1 | 0 | 2 | 0 | 0 | 0 | 189 | 98 |
| 2 | ស្រុក ភ្នំស្រុក | 4 | 26 | 1188 | 0 | 0 | 2 | 0 | 61 | 19 | 1 | 1 | 4 | 0 | 0 | 0 | 68 | 20 |
| 3 | ស្រុក ព្រះនេត្រព្រះ | 5 | 30 | 1590 | 0 | 0 | 63 | 25 | 1 | 1 | 3 | 1 | 0 | 0 | 0 | 0 | 67 | 27 |
| 4 | ស្រុក អូរជ្រៅ | 6 | 26 | 1239 | 1 | 0 | 32 | 11 | 0 | 0 | 2 | 0 | 0 | 0 | 0 | 0 | 35 | 11 |
| 5 | ក្រុង សិរីសោភ័ណ | 6 | 33 | 1340 | 2 | 0 | 90 | 46 | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 93 | 46 |
| 6 | ស្រុក ថ្មពួក | 6 | 26 | 1251 | 1 | 0 | 39 | 17 | 2 | 1 | 3 | 1 | 0 | 0 | 0 | 0 | 45 | 19 |
| 7 | ស្រុក ស្វាយចេក | 8 | 38 | 1746 | 1 | 1 | 61 | 12 | 1 | 0 | 1 | 0 | 0 | 0 | 0 | 0 | 64 | 13 |
| 8 | ស្រុក ម៉ាឡៃ | 4 | 15 | 662 | 0 | 0 | 1 | 0 | 17 | 7 | 1 | 0 | 1 | 1 | 0 | 0 | 20 | 8 |
| 9 | ក្រុង ប៉ោយប៉ែត | 5 | 32 | 1512 | 0 | 0 | 6 | 2 | 68 | 26 | 3 | 1 | 0 | 0 | 0 | 0 | 77 | 29 |
| សរុបរួម | | 54 | 294 | 13908 | 5 | 1 | 299 | 114 | 332 | 151 | 15 | 4 | 7 | 1 | 0 | 0 | 658 | 271 |

ថ្ងៃពុធ ៧រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
បន្ទាយមានជ័យ, ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩
ជ-ប្រធានការិយាល័យបុគ្គលិក
អនុប្រធាន

សម សុស

បានឃើញ និងឯកភាព
ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
អនុប្រធាន

ទិម តាំងស៊ុន